# مدرسة اهل البيت

# សាលា
# អាស្ហ់លុល-បៃត៍

## សៀវភៅ ហ្វីក្ហេះហ៍ ថ្នាក់ទី ៥ (អាយុ ៩-១០ ឆ្នាំ)

រ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ - អធិប្បាយ ១ ....................................................................៣
មេរៀនទី ២ - អធិប្បាយ ២ ....................................................................៧
មេរៀនទី ៣ - អធិប្បាយ ៣ ....................................................................១០
មេរៀនទី ៤ - អ៊ូស្វ៊ូល អ៊ុដ្វខ្វីន ....................................................................១២
មេរៀនទី ៥ - សន្ទនាខ្លីៗអំពី អ៊ូស្វ៊ូល អ៊ុដ្វខ្វីន ១ ....................................................................១៥
មេរៀនទី ៦ - សន្ទនាខ្លីៗអំពី អ៊ូស្វ៊ូល អ៊ុដ្វខ្វីន ២ ....................................................................១៩
មេរៀនទី ៧ - ហ្វ៊ូរអ៊ុដ្វខ្វីន ១ ....................................................................២២
មេរៀនទី ៨ - ហ្វ៊ូរអ៊ុដ្វខ្វីន ២ ....................................................................២៥
មេរៀនទី ៩ - រ្វឌុអ៊៍ ....................................................................២៨
មេរៀនទី ១០ - អាស្មាន និង អ៊ីក្ទ៍ម៉ាស់ ....................................................................៣២
មេរៀនទី ១១ - ស្វ៍ឡាត់ ....................................................................៣៨
មេរៀនទី ១២ - ការរៀបចំខ្លួនបំពេញស្វ៍ឡាត់ ....................................................................៤១
មេរៀនទី ១៣ - សំលៀកបំពាក់ស្វ៍ឡាត់ ....................................................................៤៣
មេរៀនទី ១៤ - កន្លែងបំពេញស្វ៍ឡាត់ ....................................................................៤៦
មេរៀនទី ១៥ - ពេលស្វ៍ឡាត់ ....................................................................៤៨
មេរៀនទី ១៦ - ណាយ៉្ជាសាស់ (نجسة) ....................................................................៥០
មេរៀនទី ១៧ - តាក្ទលីដ្វ ....................................................................៥៣
មេរៀនទី ១៨ - សាឡើងវិញ ....................................................................៥៦
មេរៀនទី ១៩ - ទង្វើវ៉ាយ៉្ជីបក្នុងស្វ៍ឡាត់ ....................................................................៦១

**មេរៀនទី ១**

# អធិប្បាយ ១

## វ៉ាយិប (وجب)

វ៉ាយិបមានន័យថាចាំបាច់ ។ បើសិនជាអ្វីមួយជាវ៉ាយិប យើងត្រូវតែធ្វើជាចាំបាច់ ព្រោះអល់ឡោះហ្វ៍ឲ្យយើងធ្វើ ។ អល់ឡោះហ្វ៍បានប្រោសប្រណីយើងច្រើនណាស់ ។ ដើម្បីមិនភ្លេចព្រះគុណព្រះអង្គ ពេលណាព្រះអង្គឲ្យយើងធ្វើអ្វីមួយ យើងត្រូវតែធ្វើតាមព្រះអង្គ ។

បើយើងធ្វើទង្វើវ៉ាយិប យើងនឹងបានទទួលរង្វាន់ (ស្វាវ៉ាប់) ពីអល់ឡោះហ្វ៍ ។ បើយើងមិនធ្វើទង្វើវ៉ាយិបនោះទេ វាជាអំពើបាបមួយ ហើយយើងនឹងត្រូវទទួលទណ្ឌកម្មពីអល់ឡោះហ្វ៍ ។

ឧទាហរណ៍ ទង្វើវ៉ាយិបមាន ៖
ស្វ៍ឡាត្ហ៍ (ការធ្វើនមស្ការបូជាអល់ឡោះហ្វ៍) ស្វៅម៍ (កាន់សីលត្រណមអាហារ) ស្ហាកាត្ហ៍ (ដាក់ទាន) ។

## ស៊ូណាត្ហ៍ (سنة)

ទង្វើស៊ូណាត្ហ៍ជាទង្វើប្រសើរដែលគប្បីធ្វើ ព្រោះអល់ឡោះហ្វ៍ទ្រង់សព្វព្រះហឫទ័យ ។ ក៏ប៉ុន្តែវាមិនមែនជាទង្វើវ៉ាយិបទេ ។ មានទង្វើស៊ូណាត្ហ៍ច្រើនដែលព្រះសាស្តាﷺបានបង្ហាត់បង្រៀនយើង ។

ការពិត រាល់ពេលដែលព្រះសាស្តាﷺមានទម្លាប់ធ្វើអ្វីៗ យើងគប្បីធ្វើអ្វីនោះដែរ ព្រោះវាជាស៊ូណាត្ហ៍ ។

បើយើងធ្វើទង្វើស៊ូណាត់ អល់ឡោះហ្វ៍عز وجلនឹងប្រទានរង្វាន់ (ស្នារ៉ាប់) ឲ្យយើង តែបើយើងមិនធ្វើទេ នឹងមិនមានបាបទេ ។

ឧទាហរណ៍ទង្វើស៊ូណាត់ ៖
សូត្រព្រះគម្ពីរគួរអាន ទៅមើលអ្នកជម្ងឺ និងជួយជនក្រីក្រ ។

## ហ្ការ៉ាំ (حَرَام)

ហ្ការ៉ាំ មានន័យថា ហាម ។ បើអ្វីមួយត្រូវហាម យើងចាំបាច់មិនត្រូវធ្វើអ្វីនោះជាដាច់ខាត ពីព្រោះវានឹងធ្វើឲ្យអល់ឡោះហ្វ៍عز وجلមិនសព្វព្រះហឫទ័យ ។ ពេលណាយើងធ្វើអំពើហ្ការ៉ាំ ពេលនោះយើងបានធ្វើអំពើបាប អល់ឡោះហ្វ៍عز وجلនឹងធ្វើទណ្ឌកម្មយើង ។ បើយើងមិនធ្វើអំពើបាបទេ អល់ឡោះហ្វ៍عز وجلនឹងឲ្យរង្វាន់យើង ។

អំពើហ្ការ៉ាំ ជាឧទាហរណ៍ មានដូចជា ៖

ហូបសាច់ជ្រូក មិនស្តាប់ឪពុកម្តាយ និងនិយាយកុហក ជាដើម ។

## ម៉ាក់រុះហ្វ៍ (مكروه)

ទង្វើម៉ាក់រុះហ្វ៍គឺទង្វើដែល យកល្អ យើងគប្បីចៀសវាងធ្វើ ពីព្រោះវាមិនធ្វើឲ្យអល់ឡោះហ្វ៍عز وجلទ្រង់សព្វព្រះហឫទ័យទេ ។ ក៏ប៉ុន្តែវាមិនមែនទង្វើហ្ការ៉ាំទេ ។ បើយើងចៀសវាង មិនធ្វើទង្វើម៉ាក់រុះហ្វ៍ទេ អល់ឡោះហ្វ៍عز وجلនឹងឲ្យរង្វាន់យើង តែបើយើងធ្វើទង្វើនោះ យើងមិនបានធ្វើអំពើបាបទេ ។

ទង្វើម៉ាក់រុះហ្វ៍ ជាឧទាហរណ៍ មានដូចជា ៖

និយាយដោយប្រើសម្តីធំ ជក់បារី ដេកច្រើន ជាដើម ។

## មូបាស៊ (مباح)

ទង្វើមូបាស៊គឺទង្វើដែលគេអនុញ្ញាតឲ្យធ្វើ ។ ទោះធ្វើទង្វើនោះក្តី មិនធ្វើទង្វើនោះក្តី នឹងមិនមានរង្វាន់ ហើយក៏មិនមានបាបទេដែរ ។ មានពាក្យមួយទៀតមានន័យដូចមូបាស៊ដែរ គឺពាក្យថា យ៉ាអ៊ីស (جائز) ដែលមានន័យថាអនុញ្ញាត ។ ក៏ប៉ុន្តែគេអាចទទួលបាននូវរង្វាន់បើគេធ្វើដើម្បីអល់ឡោះហ្វ៎ ។ ឧទាហរណ៍ ៖ យើងគប្បីថា "ប៊ីសមិលឡាហ្វ៎" មុនហូបបាយ ។

ទង្វើមូបាស៊ ជាឧទារណ៍ មានដូចជា ៖
ហូប ផឹក ធ្វើកីឡា ជាដើម ។

# លំហាត់

ចូរឆ្លើយសំណួរ ថាទង្វើទាំងខាងក្រោមនេះជាទង្វើ ហ្ការ៉ាំ ស៊ូណាត់ ម៉ាក់រុះហ្វ៍ ឬ មូបាស៊ុ ?

១ ពាក់ស្បែកជើងខ្មៅ ។ _______________
២ ហូប ប៊ីកគី នៅឯហាងម៉ាក់ដូណាល់ដ៍ ។ _______________
៣ ងូតទឹកថ្ងៃសុក្រ ។ _______________
៤ ធ្វើដំណើរក្នុងខែរ៉ម៉ាដូន ។ _______________
៥ ស្តាប់ឪពុកម្តាយ ។ _______________
៦ ធ្វើដំណើរក្នុងខែស្វ៊ហ្វារ ។ _______________
៧ នៅតែហូបពេលឆ្អែតហើយ ។ _______________
៨ ស្តាប់តន្ត្រី ។ _______________
៩ កាត់ក្រចកថ្ងៃព្រហស្បត៍ ។ _______________
១០ ធ្វើស្វឡាត់ក្នុងពេលកំណត់ ។ _______________

**មេរៀនទី ២**

# អធិប្បាយ ២

## មុស្លីម

មុស្លីមគឺអ្នកដែលចុះចូលក្រោមព្រះឆន្ទៈអល់ឡោះហ្វ៍﷿ ។ ពោលគឺអ្នកនោះមិនត្រូវប្រឆាំងគោលបំណងអល់ឡោះហ្វ៍﷿ទេ ។ មុស្លីមជឿព្រះតែមួយគត់ជឿព្រះសាស្ដាទាំងឡាយ﵈របស់អល់ឡោះហ្វ៍﷿ និងជឿថាមានថ្ងៃជំនុំជម្រះ ។ អ្នកណាដែលសូត្រកាលីម៉ាស្ញ់ (كلمة) ដោយយល់ន័យ គេហៅអ្នកនោះថាមុស្លីម ។

របៀបសូត្រកាលីម៉ាស្ញ់មានដូចតទៅគឺ ៖

*ឡា អ៊ីឡាហ្វា អ៊ីលឡុលឡោះហ្វ៍* មានន័យថា៖ មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍﷿ ទេ ។
*មូហ្ហាំម៉ាដ្ញ់ឌូរ រ៉ស៊ូលុលឡោះហ្វ៍* មានន័យថា៖ មូហ្ហាំម៉ាដ្ញ់ជាព្រះសាស្ដារបស់អល់ឡោះហ្វ៍ ។

អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត្ញ់ ៣ អាលី អ៊ីមរ៉ន អាយ៉ាស្ញ់ ១០២) ថា៖
*"ឱបណ្ដាអ្នកមានសទ្ធាអើយ ពួកអ្នកចូរខ្លាចក្រែងអល់ឡោះហ្វ៍ដោយការខ្លាចក្រែងពិតប្រាកដ ហើយចូរពួកអ្នកកុំស្លាប់ក្រៅភាពជាមុស្លិមឡើយ ។"*

## មុមីន(مؤمن)

មុមីនមានកម្រិតខ្ពស់ជាងមុស្លីម ។ មុមីនជឿព្រះតែមួយ ជឿព្រះសាស្ដា﵈ទាំងឡាយរបស់អល់ឡោះហ្វ៍﷿ និងជឿថ្ងៃជំនុំជម្រះ ដូចមុស្លីមដែរក៏ប៉ុន្តែគេជឿ

យុត្តិធម៌របស់ អល់ឡោះហ្វ៍និងជឿអ៊ីមុាំទាំង ១២ عليهم السلام ។

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត៍ ៤៩ អាល់-ហ៊្វូយ៉ូរ៉ត់ អាយ៉ាស់ ១៥) ថា៖
*"បណ្ដាមុមីនគឺជនទាំងឡាយដែលមានសទ្ធាចំពោះអល់ឡោះហ្វ៍ និងសាស្ដាព្រះអង្គ បន្ទាប់មកពួកគេមិនសង្ស័យទេ ហើយពួកគេតស៊ូនៅលើមាគ៌ាអល់ឡោះហ្វ៍ដោយទ្រព្យនិងខ្លួន ។ ជនទាំងនោះជាអ្នកសច្ចៈ ។"*

## ស៊ាហ៊ីដ៍ (زهد)

គឺបុគ្គលដែលមិនសូវចូលចិត្តវត្ថុរបស់របរនានាក្នុងលោកនេះ ។ ប្រសិនបើគេបានទទួលអ្វីមួយប្រសើរ គេមិនរីករាយដល់ថ្នាក់ភ្លេចអល់ឡោះហ្វ៍ﷻទេ ។ បើគេជួបប្រទះសេចក្ដីអាក្រក់ អកុសល គេមិនរន្ធត់ដល់ថ្នាក់ភ្លេចអល់ឡោះហ្វ៍ﷻទេ ។ គេពេញចិត្តចំពោះព្រះឆន្ទៈអល់ឡោះហ្វ៍ﷻជានិច្ច ហើយមិនត្អូញត្អែរដាក់ព្រះអង្គﷻទេ ។ គេជាបុគ្គលដែលមានសេចក្ដីសោមនស្ស ។

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ ៥៧ អាយ៉ាស់ ២៣) ថា ៖
*"ដើម្បីនឹងកុំឲ្យពួកអ្នកអស់សង្ឃឹមពីព្រោះអ្វីមួយដែលបានរបូតផុតពីពួកអ្នក និងដើម្បីនឹងកុំឲ្យពួកអ្នកសប្បាយរីករាយជ្រុលពេកនឹងអ្វីមួយដែលគេបានប្រទានឲ្យពួកអ្នក ។ អល់ឡោះហ្វ៍ពុំសព្វព្រះហឫទ័យបុគ្គលណាដែលព្រហើនមានអំនួតទេ ។"*

## មុតតាគ៊ី (متقي)

នេះគឺបុគ្គលដែលជឿស៊ប់ចិត្ត ពោលគឺ គេចងចាំជានិច្ចនូវព្រះឆន្ទៈអល់ឡោះហ្វ៍ﷻ ។ គេមិនធ្វើអ្វីមួយដែលអល់ឡោះហ្វ៍ﷻហាមទេ គេធ្វើជានិច្ចនូវអ្វីដែលអល់ឡោះហ្វ៍ﷻចង់ឲ្យយើងធ្វើ ។ យើងទាំងអស់គ្នាគប្បីព្យាយាមប្រព្រឹត្តខ្លួនជាមុតតាគ៊ី ។

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ ២ អាយ៉ាស់ ១៨៣) ថា ៖

*"បណ្ដាអ្នកមានសទ្ធាអើយ គេបានដាក់បញ្ញត្តិលើពួកអ្នកឲ្យកាន់សីលអត់អាហារ ដូចដែលធ្លាប់បានដាក់បញ្ញត្តិលើបណ្ដាអ្នកសម័យមុនពួកអ្នក រួចមកហើយដែរ ដើម្បីពួកអ្នកនឹងមានសទ្ធាធិមុត្ត[ចំពោះអល់ឡោះហ្វ] ។"*

**មេរៀនទី ៣**

# អធិប្បាយ ៣

## កាហ្វៀរ (كافر)

កាហ្វៀរគឺបុគ្គលដែលមិនជឿអល់ឡោះហ្វ៍ ﷿ មិនជឿបណ្តាព្រះសាស្តា ﵇ មិនជឿបណ្តាអ៊ីម៉ាំ ﵇ ឬថ្ងៃជំនុំជម្រះទេ ។ បុគ្គលនេះមិនមែនមុស្លីមទេ ។

អល់ឡោះហ្វ៍ ﷿ មានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ ២ អាយ៉ាស់ ១៦១) ថា ៖
*"បណ្តាពួកបដិសេធសទ្ធាដែលស្លាប់នៅក្នុងភាពឥតសទ្ធា ពួកគេនឹងត្រូវបណ្តាសាអល់ឡោះហ្វ៍ផង បណ្តាទេវតាផង និងបណ្តាមនុស្សផង ។"*

## មុស្ហរិក្ហ (مشرك)

អ្នកមុស្ហរិកជឿថាអល់ឡោះហ្វ៍ ﷿ មានសហការី (ដៃគូ) ពោលគឺអ្នកនោះមិនជឿព្រះតែមួយទេ ។ នេះគឺបាបធំមួយដែលអល់ឡោះហ្វ៍ ﷿ មិនលើកលែងឲ្យទេ ។

អល់ឡោះហ្វ៍ ﷿ មានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ ៦ អាយ៉ាស់ ១០៦) ថា ៖
*"ចូរអ្នកប្រតិបត្តិតាមអ្វីដែលបានបើកឲ្យអ្នកដឹង [ដែលមក]ពីម្ចាស់របស់អ្នក ។ ពុំមានព្រះផ្សេងពីព្រះអង្គឡើយ ។ ចូរអ្នកគេចចេញពីបណ្តាអ្នកដែលយកអ្វីផ្សេង (ពួករូបបដិមា...) មកចូលរួមហ៊ុនហាយជាមួយអល់ឡោះហ្វ៍ ។"*

## មូណាហ្វិក្ហ (منافق)

អ្នកមូណាហ្វិក្ហគឺអ្នកដែលថាខ្លួនជាមុស្លីម តែនៅក្នុងចិត្តអ្នកនោះមិនប្រតិបត្តិតាមសាសនាអ៊ីស្លាមទេ ។ អ្នកនេះជាអ្នកលាក់ពុត ។ មនុស្សប្រភេទនេះជាមនុស្សភូតភរ

បោកប្រាស់ ធ្វើឲ្យអល់ឡោះហ្វ៍ទ្រង់ព្រះពិរោធបំផុត ។
អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត្ហ៍ ៤ អាយ៉ាស្ហ៍ ១៣៨) ថា ៖
*"ចូរអ្នកប្រកាសចំពោះបណ្ដាពួកមានពុតត្បុតថា ពួកគេនឹងទទួលទណ្ឌកម្មដ៏ឈឺចាប់ ។"*

## ហ្វាស៊ីក្ហ (فاسق)

អ្នកហ្វាស៊ីក្ហគឺអ្នកដែលមិនស្ដាប់បង្គាប់អល់ឡោះហ្វ៍ﷻដោយចេតនា ។ អ្នកនេះធ្វើអំពើបាបដោយចេញមុខឲ្យអ្នកផងទាំងឡាយឃើញ ។ មនុស្សបែបនេះដែលហ៊ានប្រព្រឹត្តបំពានដាក់អល់ឡោះហ្វ៍ﷻចំពោះមុខអ្នកផងដទៃ ជាប្រភេទមនុស្សសាងបាបកម្មអាក្រក់បំផុត ហើយដើរតាមគន្លងមារស្ហៃតូន ។

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត្ហ៍ ១៨ អាយ៉ាស្ហ៍ ៥០) ថា ៖
*"កាលដែលយើងមានតម្រាស់ចំពោះទេវតាទាំងឡាយថា៖ "ចូរអ្នកទាំងឡាយក្រាបប្រណិប័តន៍អាដាំ ។" ពួកគេ[ទាំងអស់]បានក្រាបប្រណិប័តន៍ លើកលែងតែអ៊ិបលិស (មារស្ហៃតូន) ទេដែលជាម្នាក់ក្នុងចំណោមពួកជិនទាំងឡាយ ។ គេបានប្រព្រឹត្តល្មើសព្រះបញ្ជាម្ចាស់គេ ។"*

**មេរៀនទី ៤**

# អ៊ូស៊្វូល អ៊ុដ្ឌីន

អ៊ូស៊្វូល អ៊ុដ្ឌីន គឺឫសកែវរបស់សាសនាយើង ។ គេហៅឫសកែវនោះផ្សេងទៀតថា អ៊ាក៏អ៊ីដ្ឋ (عقائد) ពោលគឺ គ្រឹះសាសនាយើង ។ ឫសកែវនោះមានប្រាំគឺ ៖

## ១. តៅហ៊ីដ្ឋ (មានអល់ឡោះហ្វ៍មួយគត់)

តៅហ៊ីដ្ឋមានន័យថា អល់ឡោះហ្វ៍គឺព្រះតែមួយគត់ ។ ព្រះអង្គមិនមានដៃគូ ឬសហការីទេ ។ ព្រះអង្គមិនមានឪពុកម្ដាយ មិនមានកូនទេ ។ ព្រះអង្គមិនត្រូវការអ្វី និងមិនត្រូវការអ្នកណាឡើយ តែទាំងអស់ត្រូវការព្រះអង្គ ។ ពុំមានអ្វីដូចព្រះអង្គឡើយ ។

## ២. អ៊ាដាឡាត់ (យុត្តិធម៌អល់ឡោះហ្វ៍)

អ៊ាដាឡាត់ មានន័យថា អល់ឡោះហ្វ៍ទ្រង់យុត្តិធម៌ ។ ព្រះអង្គមិនសាហាវឃោរឃៅទេ ។ ព្រះអង្គតបស្នងទាំងអស់គ្នាតាមទង្វើរបស់ម្នាក់ៗ ។ អ្នកណាគោរពតាមព្រះបញ្ញាទាំងឡាយរបស់ព្រះអង្គ អ្នកនោះនឹងត្រូវតបស្នងដោយបានទទួលនូវទីសំណាក់នៅឋានសួគ៌ ។ អ្នកណាប្រឆាំងព្រះអង្គ អ្នកនោះនឹងត្រូវបោះទៅក្នុងឋាននរក ។

## ៣. នូប៊ូវ៉ាត់ (តំណែងសាស្ដា)

នូប៊ូវ៉ាត់មានន័យថាតំណែងសាស្ដា ។ គឺជំនឿលើបណ្ដាសាស្ដាដែលអល់ឡោះហ្វ៍បានចាត់បញ្ជូនតរៀងមកដើម្បីដឹកនាំមនុស្ស ។ អល់ឡោះហ្វ៍បានចាត់បញ្ជូនមក ១២៤០០០ សាស្ដា ។ ព្រះសាស្ដាអាដាំﷺជាព្រះសាស្ដាដំបូងបង្អស់ ព្រះសាស្ដា

មូហាំម៉ាដ់ﷺជាព្រះសាស្តា ចុងក្រោយបង្អស់ដែលអល់ឡោះហ្វ៍عزوجلបានចាត់បញ្ជូនមក ។

## ៤. អ៊ីម៉ាម៉ាត់ (អ្នកស្នងព្រះសាស្តា)

បន្ទាប់ពីព្រះសាស្តាមូហាំម៉ាដ់ﷺបានចូលទិវង្គតទៅ ភារកិច្ចដឹកនាំបណ្តាមុស្លីមធ្លាក់មកលើបណ្តាអ៊ីមុាំعليهم السلام ។ អល់ឡោះហ្វ៍បានជ្រើសរើស ១២ អ៊ីមុាំعليهم السلام ។ អ៊ីមុាំ អាលីصلوات الله عليهជាអ៊ីមុាំទីមួយ អ៊ីមុាំ ម៉ាស្ទ់ឌីصلوات الله عليه والسلامជាអ៊ីមុាំចុងក្រោយ ។

ព្រោះតែអល់ឡោះហ្វ៍عزوجلមានព្រះបំណាង បានជាអ៊ីមុាំម៉ាស្ទឌីصلوات الله عليه والسلامមានព្រះជន្មាយុនៅឡើយសព្វថ្ងៃនេះ ។ ព្រះអង្គصلوات الله عليه والسلامជាអ៊ីមុាំរបស់សម័យកាលយើង ។

## ៥. គីយ៉ាម៉ាត់ (ថ្ងៃជំនំជម្រះ)

គីយ៉ាម៉ាត់ មានន័យថា ថ្ងៃជំនុំជម្រះ ឬ ថ្ងៃរស់ពីស្លាប់វិញ ។ គឺថ្ងៃដែលយើងរាល់គ្នានឹងរស់ឡើងវិញដើម្បីជម្រះក្តីអំពីទង្វើទាំងឡាយដែលយើងបានធ្វើ ។ បន្ទាប់មកយោលតាមលទ្ធផលនៃទង្វើទាំងឡាយរបស់ខ្លួន ម្នាក់ៗនឹងត្រូវតបស្នងដោយបានចូលឋានសួគ៌ ឬដោយត្រូវបញ្ជូនទៅធ្វើទណ្ឌកម្មនៅឋាននរក ។

# លំហាត់

ដូចដើមឈើដែលត្រូវការឫសមាំ មុស្លីមល្អក៏ត្រូវតែយល់យ៉ាងជ្រាលជ្រៅនិងជឿជាក់លើឫសកែវរបស់សាសនាជាចាំបាច់ដែរ ។

លើរូបភាពខាងក្រោមនេះ ចូរបំពេញន័យរបស់ពាក្យអារ៉ាប់ទាំងឡាយរបស់អ៊ូស្វូល អ៊ុដ្ឌីន ។



## មេរៀនទី ៥

# សន្ទនាខ្លីៗអំពី អ៊ូស៊្វូល អ៊ុដ្ឌ៊ីន ១

### ១. តៅហ៊ីដ្ (មានអល់ឡោះហ៍តែមួយគត់)

ថ្ងៃមួយ ព្រះសាស្ដាﷺនិងសាវ័កពីរបីនាក់របស់ព្រះអង្គﷺបានដើរមើល ហើយបានឃើញជីដូនម្នាក់ប្រកបកិច្ចការដោយត្បាល់កិន ដោយបួងសួងសូមឲ្យអល់ឡោះហ៍ប្រោសប្រណី ។ ព្រះសាស្ដាﷺបានចូលទៅសួរសុខទុក្ខគាត់ ។ ព្រះអង្គﷺបានសួរគាត់ថា៖ "ការជឿជាក់របស់លោកយាយលើអល់ឡោះហ៍ﷻគួរឲ្យសរសើរណាស់ ។ លោកយាយប្រាប់ខ្ញុំﷺបានទេថាអ្វីទៅដែលធ្វើឲ្យលោកយាយជឿជាក់លើអល់ឡោះហ៍ﷻ ?"

បានឮដូច្នេះហើយ ជីដូនបានឈប់កិនមួយសន្ទុះ គាត់បានជញ្ជឹងគិតមួយភ្លែត ហើយបានថា៖ "រ៉ស៊ូលុលឡោះហ៍ﷺអឺយ ! ព្រះអង្គﷺឃើញត្បាល់កិននេះទេ វាមិនអាចកម្រើកបានទេដរាបណាខ្ញុំម្ចាស់មិនបង្វិលវា ។ ត្បាល់កិនតូចមួយនេះអាចវិលបាន ចុះហេតុអ្វីភពផែនដែនចក្រវាលដែលមហាធំធេងអាចដំណើរការទៅបានយ៉ាងល្អប្រសើរ ដោយគ្មានកម្លាំងនីមួយអូសវានោះ ? ត្រូវតែមានអ្នកណាម្នាក់ធ្វើឲ្យវាដំណើរការទៅបានជាចាំបាច់ ។ អ្នកដែល បញ្ជាសព្វបែបយ៉ាងបានមិនមែនអ្នកណាក្រៅពីអល់ឡោះហ៍ﷻទេ ព្រះអ្នកបង្កើត ព្រះម្ចាស់សព្វសារពើ ។

រ៉ស៊ូលុលឡោះហ៍ﷺមានសេចក្ដីសោមនស្សអនេក អំពីចម្លើយរបស់ជីដូនរូបនេះ ។ ព្រះអង្គﷺបានប្រាប់បណ្ដាសាវ័កព្រះអង្គﷺថា៖ "អស់លោកឃើញជីដូនរូបនេះទេ គាត់យល់អល់ឡោះហ៍ﷻយ៉ាងងាយស្រួលបំផុត ។ ជំនឿរបស់អស់លោកលើអល់ឡោះហ៍ﷻគួរតែមាំមួនដូចជំនឿគាត់ដែរ ។"

### ២. អ៊ុដ្ឌាឡាត្អ់ (យុត្តិធម៌អល់ឡោះហ៍)

យុត្តិធម៌អល់ឡោះហ្វមិនមានន័យថា អល់ឡោះហ្វស្មើភាពចំពោះទាំងអស់គ្នានោះទេ ។ ស្មើភាពនិងត្រឹមត្រូវមិនដូចគ្នាទេ ។

ពេលគេប្រើពាក្យយុត្តិធម៌សម្រាប់អល់ឡោះហ្វ មានន័យថាព្រះអង្គរក្សាឲ្យមានលំនឹងរវាងសេចក្តីត្រូវការរបស់ជីវន្តលោកទាំងអស់របស់ព្រះអង្គ ។

រឿងតំណាលតទៅនេះនឹងឲ្យអ្នកយល់បានថា អល់ឡោះហ្វទ្រង់ព្រះអាឌិល (គឺយុត្តិធម៌) ដូចម្តេចខ្លះ ។

គ្រូពេទ្យម្នាក់ អ្នកធ្វើនំប័ុងម្នាក់ និងចោរម្នាក់ រស់នៅក្នុងស្រុកមួយ ។ រៀងរាល់ព្រឹកទាំងបីនាក់នេះបួងសួងអល់ឡោះហ្វ សូមឲ្យព្រះអង្គបង្កើនព្រះឧបការគុណមកលើពួកគេ ។

ថ្ងៃនេះ បុរសចោរមានគម្រោងការលួចបុរសអ្នកធ្វើនំប័ុង តែគាត់ធ្លាក់ខ្លួនឈឺ ហើយចាំបាច់ទៅជួបគ្រូពេទ្យ ។ រីឯបុរសអ្នកធ្វើនំប័ុងនោះវិញ គាត់មិនរកបានប្រាក់ច្រើនទេ ព្រោះមានភ្លៀងធ្លាក់បណ្តាលឲ្យអតិថិជនរបស់គាត់ចេញពីផ្ទះមិនរួច ។

យើងបែរមកសិក្សារឿងតំណាលនេះ ។

បុរសចោរ ព្រោះតែឈឺ ឯបុរសអ្នកធ្វើនំប័ុង ព្រោះតែភ្លៀង ហាក់ដូចជាបានទទួលនូវសេចក្តីលំអៀងពីអល់ឡោះហ្វ ។ ផ្ទុយទៅវិញ គ្រូពេទ្យបានទទួលនូវសមធម៌អល់ឡោះហ្វ ។

ដូច្នេះ តើអល់ឡោះហ្វត្រឹមត្រូវលើពួកគេរាល់គ្នាទេ ? យើងឃើញថាការមិនលំអៀងនិងការគ្មានសមធម៌ មិនអធិប្បាយពណ៌នាអត្ថន័យរបស់អាដ្ឋាឡាត្ហ៍យ៉ាងពេញលេញបានទេ ។ ដើម្បីឲ្យយល់ យើងត្រូវដឹងថាអល់ឡោះហ្វរក្សាឲ្យមាននូវលំនឹងក្នុងសេចក្តីត្រូវការរបស់សត្វលោកទាំងអស់របស់ព្រះអង្គ ។

យើងបែរមកមើលរឿងតំណាលនេះតាមទស្សនៈមួយទៀត ។

គ្រូពេទ្យត្រូវអស់ឡោះហ្វ៍ប្រោសប្រណី ព្រោះគាត់មានអតិថិជនម្នាក់ថែមទៀត ។

បុរសចោរក៏ត្រូវអស់ឡោះហ្វ៍ទ្រង់ប្រោសប្រណីដែរ ព្រោះតែគាត់ឈឺបានជាគាត់មិនបានលួចគេ ។

ឯបុរសអ្នកធ្វើនំប៉ុងក៏បានអស់ឡោះហ្វ៍ទ្រង់ប្រោសប្រណីដូចគេដែរ ព្រោះថា ថ្វីបើគាត់មិនមានប្រាក់ចំណូលច្រើនក៏ដោយ តែគាត់បានរួចផុតពីការលួចប្លន់ ។

យើងបានឃើញហើយថា អ៊ុដ្ឋាឡាត្ទុំ មានន័យថា អស់ឡោះហ្វ៍ក្តាប់ទុកនូវលំនឹងរវាងសេចក្តីត្រូវការរបស់សត្វលោកទាំងអស់របស់ព្រះអង្គ ។

# លំហាត់

ចូរអ្នកអានសម្រាយរបស់ស្វ៊េាះត្ត៍ អាត់-តៅហ្វ៊ីដ្ហ (ស្វ៊េាះត្ត៍ ១១២) ហើយចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. តើអាយ៉ាស់ទីមួយស្តីអំពីអ្វីខ្លះទាក់ទងនឹងអល់ឡោះហ្វ៍ ?

២. តើអាយ៉ាស់ទីពីរស្តីអំពីអ្វីខ្លះទាក់ទងនឹងសេចក្តីត្រូវការ ?

៣. តើអាយ៉ាស់ទីបីស្តីអំពីអ្វីខ្លះទាក់ទងនឹងបុត្រព្រះអង្គ មាតាបិតាព្រះអង្គ ?

៤. តើអាយ៉ាស់ចុងក្រោយស្តីអំពីអ្វីខ្លះទាក់ទងនឹងអល់ឡោះហ្វ៍ ?

**មេរៀនទី ៦**

# សន្ទនាខ្លីៗអំពី អ៊ូស៊ូល អ៊ុដ្ឌីន ២

**៣. នូប៊ូវាត់ (តំណែងសាស្តា)**

បុរសពីរនាក់ធ្វើដំណើរជាមួយគ្នា ហើយបានរាប់រកគ្នាជាមិត្ត ។ លុះបានដល់គោលដៅ ម្នាក់បានអញ្ជើញមិត្តខ្លួនទៅទទួលទានអាហារថ្ងៃស្អែក ។ តែគាត់មិនបានឲ្យអាសយដ្ឋាននិងលេខទូរស័ព្ទទៅមិត្តគាត់ទេ ។ មិត្តគាត់ចង់ទៅទទួលទានអាហារឯផ្ទះគាត់ តែទៅបានដូចម្តេច ? គាត់មិនដឹងនឹងធ្វើដូចម្តេចទេ ។

អល់ឡោះហ្ទ៍عزّ وجلّបានបង្កើតយើងមកដើម្បីនឹងឲ្យយើងគោរពបូជាព្រះអង្គ ។ ប្រសិនបើព្រះអង្គعزّ وجلّមិនបានចាត់បញ្ជូនព្រះសាស្តាعليهم السلامជាមគ្គុទេសក៍មករកយើងទេ តើយើងអាចគោរពបូជាព្រះអង្គعزّ وجلّបានដូចម្តេចទៅ ? ដើម្បីឲ្យយើងរកព្រះអង្គعزّ وجلّឃើញ បានជាព្រះអង្គعزّ وجلّចាត់បញ្ជូនច្រើនព្រះសាស្តាعليهم السلامមកដើម្បីបង្ហាញផ្លូវយើង ។

**៤. អ៊ីម៉ាម៉ាត់ (ឧត្តរាធិការីព្រះសាស្តា)**

ថ្ងៃមួយ បុរសម្នាក់បានសាងសង់ម៉ាស៊ីនឆ្លាតមួយ ។ គេឃើញថាវាមានប្រយោជន៍ ហើយបានទិញវាយកទៅប្រើប្រាស់ជាធម្មតា ។ មុនស្លាប់ បុរសនេះបានបង្ហាត់បង្រៀនសិស្សគាត់ឲ្យចេះជួសជុលម៉ាស៊ីន ពេលវាខូចឬដំណើរការមិនប្រក្រតី ។ ក្រោយពីគាត់បានស្លាប់ទៅ រាល់គ្រាដែលគេមានបញ្ហាជាមួយម៉ាស៊ីន គេមករកសិស្សរបស់គាត់ដើម្បីដោះស្រាយបញ្ហា ។

ដូចគ្នាដែរ ទោះបីព្រះសាស្តាصلى الله عليه وآله وسلمបាននាំមកនូវច្បាប់ទាំងអស់ក៏ដោយ ក្រោយពីព្រះអង្គصلى الله عليه وآله وسلمសោយទិវង្គតទៅ ក៏គេត្រូវការអ្នកណាម្នាក់ដែលមានសមត្ថភាពឆ្លើយតបសំណួរមនុស្សដែរ ។ អ៊ីម៉ាំعليهم السلامដែលត្រូវអល់ឡោះហ្ទ៍عزّ وجلّជ្រើសរើស ជាអ្នកបន្តវេនដើម្បីពន្យល់ភារកិច្ចរបស់ព្រះសាស្តាصلى الله عليه وآله وسلم ។

**៥. គ្ទីយ៉ាម៉ាតូ់ (ថ្ងៃជំនុំជម្រះ)**

មានបុរសមុស្លីមម្នាក់បានចាប់ផ្តើមផឹកសុរា ។ គាត់បានលួចផឹកនៅឯផ្ទះគាត់ ។ ថ្ងៃមួយ កុមារម្នាក់បានចូលក្នុងបន្ទប់គាត់ បានឃើញគាត់ ។ ពេលនេះ គាត់ខ្លាចបំផុត តើក្មេងនេះនឹងប្រាប់គេឲ្យដឹងអំពីអ្វីដែលវាបានឃើញទេ ? បុរសរូបនេះនឹងធ្វើយ៉ាងណាចំពោះមុខគ្រួសារគាត់និងមិត្តគាត់នៅឯម៉ាស់ឃ្ជិដ្ធ ? គាត់ដេកមិនលក់ ដោយសារតែគាត់បារម្ភអំពីអ្នកផងនិយាយរឿងគាត់ផឹក ។

បុរសរូបនេះប្លែកមែន ! គាត់ខ្លាចកុមារនោះជាងខ្លាចអល់ឡោះហ្វ៍ ទៅទៀត ។ អល់ឡោះហ្វ៍ មើលឃើញអ្វីសព្វគ្រប់ដែលយើងធ្វើ នឹងមានថ្ងៃមួយដែលយើងនឹងត្រូវធ្វើសេចក្តីរាយការណ៍អំពីទង្វើទាំងអស់របស់យើង ។ ថ្ងៃនោះគឺថ្ងៃជំនុំជម្រះ ។

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីអល់ឡោះហ្វ៍عزوجلបានចាត់បញ្ជូនព្រះសាស្ដាعليهم السلامមក ?
២. ហេតុអ្វីយើងត្រូវការអ៊ីម៉ាំعليهم السلام ?
៣. ហេតុអ្វីអល់ឡោះហ្វ៍عزوجلបានត្រៀមថ្ងៃជំនុំជម្រះ ?

**មេរៀនទី ៧**

# ហ្វ៊ូរអ៊ុដ្វខ៊ីន ១

ហ្វ៊ូរអ៊ុដ្វខ៊ីនជាសាខារបស់សាសនា ។ ជាកិច្ចប្រតិបត្តិក្នុងការធ្វើសក្ការបូជាអល់ឡោះហ្វ៍ដែលយើងត្រូវធ្វើ ពេលយើងបានយល់អ្វីស្វូល អ៊ុដ្វខ៊ីន ។

ហ្វ៊ូរអ៊ុដ្វខ៊ីនមាន ១០ ប្រការ គឺ ៖

**១. ស្វ៉ឡាត់ (នមស្ការប្រចាំថ្ងៃ)**

អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖
*"ចូរពួកអ្នកស្វែងរកជំនួយក្នុងអំណត់និងក្នុងនមស្ការ[បូជាអល់ឡោះហ្វ៍] ។" (២:៤៥)*

មាន ១៧ រ៉ក់អ្ាត់ក្នុងនមស្ការប្រចាំថ្ងៃគឺ ៖
ហ្វាជ្រ៍ ២ រ៉ក់អ្ាត់, ស្វ៊ហ្វូរ៍ ៤ រ៉ក់អ្ាត់, អ៊ាស្វ៉រ៍ ៤ រ៉ក់អ្ាត់, ម៉ាក់រីប ៣ រ៉ក់អ្ាត់, អ៊ីស្វាអ៍ ៤ រ៉ក់អ្ាត់ ។

**២. ស្វៅម៍ (ត្រណមអាហារក្នុងខែរ៉ម៉ាដូន)**

អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖
*"បណ្ដាអ្នកមានសទ្ធាអើយ គេបានដាក់បញ្ញត្តិលើពួកអ្នកឲ្យកាន់សីលអត់អាហារ ដូចដែលធ្លាប់បានដាក់បញ្ញត្តិលើបណ្ដាអ្នកសម័យមុនពួកអ្នករួចមកហើយដែរ ដើម្បីពួកអ្នកនឹងមានសទ្ធាធិមុត្ត[ចំពោះអល់ឡោះហ្វ៍] ។" (២:១៨៣)*

ការកាន់សីលតមអាហារក្នុងខែរ៉ម៉ាដូន ជាកាតព្វកិច្ចលើមុស្លីមគ្រប់រូបរៀងរាល់ ឆ្នាំ ។ ចាប់ផ្ដើមពីមុនថ្ងៃរះ (ស្វ៊ុបហ្វ ស្វ៉ឌិក្វ) ចប់ពេលម៉ាក់រីប (ថ្ងៃលិច) ។

### ៣. ហ្ជាច្ជ៍ (ពិធីបូជនីយេសចរណ៍នៅឯម៉ាក់កាស្ហ៍)

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖
*"ចូរពួកអ្នកបំពេញពិធីបូជនីយេសចរណ៍ (ហ្ជាច្ជ) និងអ៊ុមរ៉ោះត៍ដើម្បីអល់ឡោះហ្វ៍ ។" (២:១៩៦)*

មុស្លីមគ្រប់រូបត្រូវតែទៅបំពេញពិធីហ្ជាច្ជ៍ មួយដងក្នុងមួយជីវិតនៅឯម៉ាក់កាស្ហ៍ ពេលមានលទ្ធភាព ។

### ៤. ស្ហាកាត្ហ៍ (សទ្ធាទាន)

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖
*"បណ្ដាអ្នកមានសទ្ធា[ចំពោះអល់ឡោះហ្វ៍] ប្រព្រឹត្តអំពើល្អ បំពេញនមស្ការ[បូជាអល់ឡោះហ្វ៍] យ៉ាងខ្ជាប់ខ្ជួននិងបរិច្ចាគសទ្ធាទាន ជនទាំងនោះនឹងមានរង្វាន់នៅឯម្ចាស់ពួកគេ ។" (២:២៧៧)*

ស្ហាកាត្ហ៍ជាវិភាគទានដែលគេត្រូវតែបរិច្ចាគលើរបស់មួយចំនួន ហើយដែលគេត្រូវឲ្យទៅមុស្លីមស្ហ៊ីអាស្ហ៍ក្រីក្រ ។

### ៥. ឃុមស៍ (ពន្ធអ៊ីស្លាមមួយភាគប្រាំ)

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖
*"ចូរអ្នកទាំងឡាយដឹងថា អ្វីៗទាំងអស់ដែលពួកអ្នកបានប្រមូលយកជាទ្រព្យឈ្លើយមួយភាគប្រាំនៃអ្វីទាំងនោះជាកម្មសិទ្ធិរបស់អល់ឡោះហ្វ៍ របស់សាស្ដា" (៨:៤១) ។*

ម្នាក់ៗត្រូវបរិច្ចាគមួយភាគប្រាំនៃប្រាក់ចំណេញ (ផាត់ទាត់រួច) ក្នុងមួយឆ្នាំ ។ ចំនួនទឹកប្រាក់ត្រូវបែងចែកឲ្យទៅរាជវង្សរបស់រ៉ស៊ូលុលឡោះហ្វ៍ﷺនិងអ៊ីម៉ាំទី ១២ របស់យើង ។ ក្នុងសម័យ កុយ់បាស្ហ៍ គេឲ្យទៅមុច្ជតាហ៊្វីដ្ហ (مُجْتَهِد) ។

# លំហាត់

ចូររៀវរកអាយ៉ាស់ដទៃទៀតនៅក្នុងគូរអានដែលស្តីអំពីស្វ៍ឡាត់ ។ មើលក្នុងស្វព៉ោះត្ត័អាល់-ម៉ាអ៊ួន ហើយសរសេរសម្រាយស្វព៉ោះត្ត័នេះ ។

**មេរៀនទី ៨**

# ហ៊្សូរអ៊ីដ្ឌីន ២

**៦. យ៉ីហាដ្** (اَلْجِهَادُ **ប្រយុទ្ធដើម្បីអល់ឡោះហ្វ៍**)

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថាៈ
*"សាស្តាអើយ ចូរអ្នកលើកទឹកចិត្តអ្នកមានសទ្ធាទាំងឡាយឲ្យមានសេចក្តីក្លាហានដើម្បីប្រយុទ្ធ ។ បើមានចំនួនម្ភៃនាក់ ក្នុងចំណោមពួកអ្នក ដែលអត់ធ្មត់ ពួកគេនឹងដណ្តើមយកបាននូវជ័យជំនះលើសត្រូវដែលមានចំនួនពីររយនាក់ ។" (៨:៦៥)*

យ៉ីហ្វាដ្ឋមានន័យថាប្រយុទ្ធដើម្បីអល់ឡោះហ្វ៍ﷻ តាមការកោះហៅរបស់ព្រះសាស្តា ﷺ ឬ អ៊ីម៉ាំសម័យកាល ។ មិនមែនប្រយុទ្ធដោយអាវុធតែមួយមុខទេ អាចប្រយុទ្ធដោយសំណោរ ឬដោយសំដី ។

**៧. អាំរ៍ ប៊ិលម៉ាក្រ៊ូហ្វ** (اَلْأَمْرَ بِالْمَعْرُوفِ **ណែនាំគេឲ្យធ្វើល្អ**)

**៨. ណាស៊ុយ៉ា អ៊ុនីល-មុនការ** (اَلنَّهْيَ عَنِ الْمُنْكَرِ **ហាមគេមិនឲ្យធ្វើអាក្រក់**)

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថាៈ
*"ចូរឲ្យមាននៅក្នុងចំណោមពួកអ្នក នូវសហាគមន៍មួយដែលហៅទៅរកសេចក្តីល្អប្រពៃ បង្គាប់ឲ្យប្រព្រឹត្តល្អ[តាមព្រះគម្ពីរអល់ឡោះហ្វ៍និងតាមព្រះសាស្តាព្រះអង្គ] ហាមប្រព្រឹត្តអាក្រក់ (គឺហាមអ្វីដែលអល់ឡោះហ្វ៍ហាម) ។ ជនទាំងនោះជាជនដែលនឹងបាននូវជ័យជំនះ [បានដល់សុខុមាលភាពនៃឋានសួគ៌] ។" (៣:១០៤)*

ប្រសិនបើយើងឃើញអ្នកណាមួយធ្វើអំពើល្អ យើងគប្បីអបអរសាទរលើកទឹកចិត្តអ្នកនោះឲ្យធ្វើអំពើល្អ ។ នេះគេហៅថា អាំរ៍ ប៊ិលម៉ាក្រ៊ូហ្វ ។

ប្រសិនបើយើងឃើញអ្នកណាមួយធ្វើអំពើអាក្រក់ យើងគប្បីព្យាយាមហាមឃាត់អ្នកនោះមិនឲ្យធ្វើអំពើអាក្រក់នោះ ។ នេះគេហៅថា ណាស៊្ហ៍យ៉ា អ៊ុនីល-មុនការ ។

## ៩. តាវ៉ាល់ឡា (تَوَلَّى ស្រឡាញ់មិត្តរបស់ម៉ាក់ស៊្ហូមីនعليهم السلام)

## ១០. តាបារ៉ា (تَبَرَّأَ ស្អប់សត្រូវរបស់ម៉ាក់ស៊្ហូមីនعليهم السلام)

ព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "អ្នកណាធ្វើឲ្យបុត្រីسلام الله عليهاខ្ញុំصلى الله عليه وآله وسلمពេញចិត្ត អ្នកនោះធ្វើឲ្យខ្ញុំصلى الله عليه وآله وسلمពេញចិត្ត អ្នកណាធ្វើឲ្យបុត្រីسلام الله عليهاខ្ញុំصلى الله عليه وآله وسلمឃ្នើសចិត្ត អ្នកនោះធ្វើឲ្យខ្ញុំصلى الله عليه وآله وسلمឃ្នើសចិត្ត ។"

តាវ៉ាល់ឡាមានន័យថាប្រតិបត្តិតាមសិក្ខាបទរបស់ម៉ាក់ស៊្ហូមីនعليهم السلامទាំង ១៤ អង្គ និងរក្សាមិត្តភាពជាមួយបក្សពួករបស់ម៉ាក់ស៊្ហូមីនعليهم السلامទាំង ១៤ អង្គនោះ ។

តាបារ៉ាមានន័យថាដកខ្លួនចេញពីអ្នកណាដែលស្អប់ ឬ មិនប្រតិបត្តិតាមម៉ាក់ស៊្ហូមីនعليهم السلامទាំង ១៤ អង្គ ។

## លំហាត់

អល់ឡោះហ្ជ៍ប្រាប់យើងថា ហេតុអ្វីយើងត្រូវស្រឡាញ់ម៉ាក់ស្ទួមីននៅចុងស៊ូរ៉ោះត្ទ័ ៣៣ (អាល់-អាស្ហ្សាប់) អាយ៉ាស្ទុ ៣៣ ។

ហើយព្រះអង្គព្រមានយើងដែរ ឲ្យយើងប្រយ័តខ្លួនកុំប្រឆាំងព្រះសាស្តាﷺនៅក្នុងស៊ូរ៉ោះត្ទ័ដដែល អាយ៉ាស្ទុ ៥៧ ។

ចូរមើលសម្រាយអាយ៉ាស្ទុទាំងពីរនេះ ហើយសរសេរវានៅខាងក្រោមនេះ ។

**មេរៀនទី ៩**

# វូឌុអ៏

វូឌុអ៏ជាវិធីលាងសម្អាតពិសេសដែលធ្វើឲ្យយើងស្អាតទៅតាមសាសនា ។ វិធីវូឌុអ៏មានការលាងមុខ លាងដៃទាំងពីរ និងការជូតក្បាលប៉ែកខាងមុខ និងជើងទាំងពីរប៉ែកខាងលើ ។

ចាំបាច់ត្រូវមានទឹកវូឌុអ៏សម្រាប់ ៖

១. បំពេញស្វ៍ឡាត្ញ
២. បំពេញត៏វ៉ាហ្វ
៣. ប៉ះអក្សរសំណេរក្នុងព្រះមហាគម្ពីរគួរអាន ។
៤. ប៉ះព្រះនាមអល់ឡោះហ្វ៍ﷻនិងបុគ្គលបរិសុទ្ធ (ម៉ាក់ស៊្វូមីន) ទាំង ១៤ រូបعليهم السلام ។

**លក្ខខណ្ឌវូឌុអ៏**

១. គ្រប់ប៉ែករបស់អវយវៈដែលប៉ះទឹកវូឌុអ៏ចាំបាច់ត្រូវស្អាត (គ្មានអ្វីបិទបាំងជាដើម) ។

២. ត្រូវប្រើទឹកត៏ហ្វៀរ (គឺបរិសុទ្ធ) ទឹកមូបាស្ហ៍ (អនុញ្ញាត) និងទឹកមុតឡាក់ (គឺទឹកបរិសុទ្ធ មិនលាយអ្វីផ្សេង) ។

៣. កន្លែងយកទឹកវូឌុអ៏ត្រូវមូបាស្ហ៍ (អនុញ្ញាត) ។

៤. គោលបំណង (នៀត) គឺត្រូវតែ គួរបាតាន់ អ៊ីលឡុលឡោះហ្វ៍ (ដើម្បីទៅរកអល់ឡោះហ្វ៍ﷻ) ។

៥. តារទិប (ترتيب) ៖ ការយកទឹកវូឌុអ៊ុត្រូវប្រព្រឹត្តទៅតាមលំដាប់ ។

៦. មូវ៉ាឡាត់ (موالاة) ៖ ការយកទឹកវូឌុអ៊ុត្រូវប្រព្រឹត្តទៅមិនដាច់ (មិនឈប់យូរពេក) ។

៧. ការយកទឹកវូឌុអ៊ុត្រូវប្រព្រឹត្តទៅដោយខ្លួនឯង មិនមានគេជួយ លើកលែងតែពិការ ឬ មានជម្ងឺ ។

៨. ក្នុងពេលយកទឹកវូឌុអ៊ុ ត្រូវយកថ្នាំលាបក្រចកចេញ ដោះចិញ្ចៀន និងនាឡិកា ។ ទឹកត្រូវជ្រាបទៅដល់ប៉ែកអវយវៈទាំងនេះ ។

## ទង្វើស៊ូណាត់ក្នុងវូឌុអ៊ុ

១. លាងមុខនិងដៃទាំងពីរ ពីរដង ។

២. ខ្ពុរមាត់ ៣ ដង ។

៣. ជម្រះរន្ធច្រមុះ ៣ ដង ។

ទង្វើស៊ូណាត់ទាំងអស់ក្នុងវូឌុអ៊ុត្រូវធ្វើមុនទង្វើវ៉ាយិប ។

## ទង្វើវ៉ាយិបក្នុងវូឌុអ៊ុ

១ នៀតៈ "ខ្ញុំយកទឹកវូឌុអ៊ុដើម្បីសព្វព្រះហឫទ័យអល់ឡោះហ្វ៍ គួរបាត្ញុនអ៊ីលឡលឡោះហ្វ៍ ។"

២ លាងមុខៈ ចាប់ពីថ្ងាស (គឺពីជើងសក់) រហូតដល់ចង្កា ទទឹងក្នុងចន្លោះមេដៃនិងម្រាមកណ្តាល ។

៣ លាងដៃស្តាំៈ ចាប់ពីកែងដៃដល់ចុងម្រាបដៃ ។

៤ លាងដៃឆ្វេង៖ ចាប់ពីកែងដៃដល់ចុងម្រាមដៃ ។

៥ ម៉ាសាស្ស៊ (គឺជូត) ក្បាល៖ យកម្រាមដៃស្តាំទទឹកជូតលើក្បាល ។ អូសម្រាមដៃចាប់ពីពាក់កណ្តាលក្បាលមករកថ្ងាសដោយមិនឲ្យប៉ះទឹកលើថ្ងាស ។ ក្នុងពេលជូតនេះត្រូវឲ្យក្បាលនឹង ។

៦ ជូតជើងទាំងពីរ៖ យកម្រាមដៃស្តាំទទឹកជូតប៉ែកខាងលើរបស់ប្រអប់ជើងស្តាំ ។ អូសម្រាមដៃចាប់ពីចុងមេជើងរហូតមកដល់គន្លាក់ជើង (គឺកជើង) ។ រួចហើយជូតជើងឆ្វេងដោយវិធីដូចគ្នា ដោយប្រើដៃឆ្វេង ។

**អ្វីដែលធ្វើឲ្យខូចទឹកវូឌុអ៍**

១. បន្ទោបង់ (គឺបត់ជើងតូច បត់ជើងធំ) ។

២. ដើរខ្យល់ (គឺផោម) ។

៣. ដេកលក់

៤. បាត់បង់ស្មារតី ។

# លំហាត់

ចូរហ្វឹកហាត់តាមសេចក្តីណែនាំឲ្យស្ទាត់ ។

**មេរៀនទី ១០**

# អាសា្ហន និង អ៊ីក៏ម៉ាស្ហ

**អាសា្ហន - ប្រកាសនមស្ការ**

اَكْبَرُ اَللّٰهُ (៤ ដង)

អល់ឡោះហ្វមហាធំថ្កើងបំផុត

اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ (២ ដង)

ខ្ញុំសូមប្ដេជ្ញាថា មិនមានព្រះផ្សេងពីអល់ឡោះហ្វឡើយ ។

اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ (២ ដង)

ខ្ញុំសូមប្ដេជ្ញាថា មូហ៊ាំម៉ាដ្ហជាព្រះសាស្ដារបស់អល់ឡោះហ្វ ។

اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ (២ ដង)

ខ្ញុំសូមប្ដេជ្ញាថាអ៊ុលីជាទីស្រឡាញ់របស់អល់ឡោះហ្វ ។

حَيَّ عَلَى الصَّلَاةِ (២ ដង)

ចូរអ្នកប្រញាប់មកបំពេញនមស្ការ(បូជាអល់ឡោះហ្វ) ។

حَيَّ عَلَى الْفَلَاحِ (២ ដង)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកជោគជ័យ ។

حَيَّ عَلَى خَيْرِ الْعَمَلِ (២ ដង)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកទង្វើដ៏ល្អបំផុត ។

اَللّٰهُ اَكْبَرُ (២ ដង)

អល់ឡោះហ្វ៍មហាធំថ្កើងបំផុត

لَا اِلٰهَ اِلَّا اللّٰهُ (២ ដង)

មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ។

**អ៊ីកុំម៉ាស់ - សូត្រមុនចាប់ផ្តើមបំពេញនមស្កា(បូជាអល់ឡោះហ្វ៍) ។**

اَللّٰهُ اَكْبَرُ (២ ដងហើយ)

អល់ឡោះហ្វ៍មហាធំថ្កើងបំផុត

اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថា មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ។

اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថា មូហ៊ាំម៉ាដ់ជាព្រះសាស្តារបស់អល់ឡោះហ្វ៍ ។

اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ (២ ដងហើយ)

ខ្ញុំសូមប្តេជ្ញាថាអ៊ុលីជាទីស្រឡាញ់របស់អល់ឡោះហ្វ៍ ។

حَيَّ عَلَى الصَّلَاةِ (២ ដង)

ចូរអ្នកប្រញាប់មកបំពេញនមស្ការ(បូជាអល់ឡោះហ្វ) ។

حَيَّ عَلَى الْفَلَاحِ (២ ដងហើយ)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកជោគជ័យ ។

حَيَّ عَلَى خَيْرِ الْعَمَلِ (២ ដងហើយ)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកទង្វើដ៏ល្អបំផុត ។

قَدْ قَامَتِ الصَّلَاةِ (២ ដង)

នមស្ការ(ស្វ៊ឡាត្ទុ)ចាប់ផ្តើមហើយ ។

اَللّٰهُ اَكْبَرُ (២ ដងហើយ)

អល់ឡោះហ្វមហាធំធ្ងើងបំផុត

لَا اِلٰهَ اِلَّا اللّٰهُ (១ ដងហើយ)

មិនមានព្រះផ្សេងពីអល់ឡោះហ្វឡើយ ។

**តារាងប្រៀបធៀបអាស្ទាន និង អ៊ីក៏ម៉ាស្ទ**

| របៀបសូត្រ | អាស្ទាន | អ៊ីក៏ម៉ាស្ទ |
|---|---|---|
| اَللّٰهُ اَكْبَرُ<br>អល់ឡោះហ្វមហាធំធ្ងើងបំផុត | ៤ ដង | ២ ដង |
| اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ<br>ខ្ញុំសូមប្តេជ្ញាថា មិនមានព្រះផ្សេងពីអល់ឡោះហ្វឡើយ ។ | ២ ដង | ២ ដង |
| اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ<br>ខ្ញុំសូមប្តេជ្ញាថាមូហាំម៉ាដ្ទជាព្រះសាស្តារបស់អល់ឡោះហ្វ ។ | ២ ដង | ២ ដង |

| | | |
|---|---|---|
| اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ<br>ខ្ញុំសូមប្តេជ្ញាថាអាលីជាទីស្រឡាញ់របស់អល់ឡោះហ៍្វ ។ | ២ ដង | ២ ដង |
| حَيَّ عَلَى الصَّلَاةِ<br>ចូរអ្នកប្រញាប់មកបំពេញនមស្ការ(បូជាអល់ឡោះហ៍្វ) ។ | ២ ដង | ២ ដង |
| حَيَّ عَلَى الْفَلَاحِ<br>ចូរអ្នកប្រញាប់ឆ្ពោះទៅរកជោគជ័យ ។ | ២ ដង | ២ ដង |
| حَيَّ عَلَى خَيْرِ الْعَمَلِ<br>ចូរអ្នកប្រញាប់ឆ្ពោះទៅរកទង្វើដ៏ល្អបំផុត ។ | ២ ដង | ២ ដង |
| قَدْ قَامَتِ الصَّلَاةِ<br>នមស្ការ(ស្វ៍ឡាត្ទ៍)ចាប់ផ្តើមហើយ ។ | ០ ដង | ២ ដង |
| اَللّٰهُ اَكْبَرُ<br>អល់ឡោះហ៍្វមហាធំធ្វើងបំផុត | ២ ដង | ២ ដង |
| لَا اِلٰهَ اِلَّا اللّٰهُ<br>មិនមានព្រះផ្សេងពីអល់ឡោះហ៍្វឡើយ ។ | ២ ដង | ១ ដង |

## លក្ខខណ្ឌរបស់អាស្ទាននិងអ៊ីក៏្វម៉ាស្ទ៍

១. សូត្រអាស្ទាននិងអ៊ីក៏្វម៉ាស្ទ៍មុនបំពេញស្វ៍ឡាត្ទ៍វ៉ាយិ៍បប្រចាំថ្ងៃ ជាស៊ូណាត្ទ៍សម្រាប់គ្រប់គ្នា ។ ក៏ប៉ុន្តែ សម្រាប់ស្វ៍ឡាត្ទ៍ដែលមិនមែនស្វ៍ឡាត្ទ៍ប្រចាំថ្ងៃ ដូចជាស្វ៍ឡាត្ទ៍អ៊ីដ្ទជាដើម ដែលធ្វើរួមគ្នា (យ៉ុមអាត្ទ៍) ស៊ូណាត្ទ៍ឲ្យសូត្រថា "អាស្វ៍-ស្វ៍ឡាត្ទ៍" ៣ ដង មុនចាប់ផ្តើមបំពេញស្វ៍ឡាត្ទ៍ ។

២. ចាំបាច់ត្រូវសូត្រក្រោយពីពេលស្វ៍ឡាត្ទ៍ចូលមកដល់ មិនឲ្យសូត្រមុនទេ ។

៣. ចាំបាច់ត្រូវសូត្រជាភាសាអារ៉ាប់ត្រឹមត្រូវ (ម៉ាក់រ៉ូវ្ហ៍) ។ មិនត្រូវសូត្រដូចគេច្រៀងទេ នឹងធ្វើឲ្យបាទិ្ទល (ខូច) ។

៤. មិនត្រូវឈប់ខុសធម្មតាទេ នៅចន្លោះឃ្លានីមួយៗ ។

៥. ស្ទូណាត់ឲ្យស្ទូត្រស្វាត់ៗតាមអ្នកស្ទូត្រត្រង់កន្លែងដែលបានឮ ។

៦. ស្ទូណាត់ឲ្យអ្នកស្ទូត្រមានទឹកវង្គន្ធ័ និងឈរបែរមុខទៅរកគ្នីបឡាស់ក្នុងអំឡុងពេលស្ទូត្រអាស្វាន ។ គប្បីដាក់ដៃលើត្រចៀកនិងប្រើសម្លេងខ្លាំង ។ គប្បីឈប់បន្តិចក្នុងចន្លោះឃ្លានីមួយៗ និងមិននិយាយស្តីជាមួយគេក្នុងអំឡុងពេលស្ទូត្រនេះ ។

## លំហាត់ ១

សូមឪពុកម្តាយអ្នកឲ្យលោកបង្ហាញអ្នក ។

## លំហាត់ ២

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ពេលណាចាំបាច់ត្រូវមានវ្ញុអ៊ី ?

២. អ្វីទៅលក្ខខណ្ឌវ្ញុអ៊ី ទាក់ទងនឹងទឹក ?

៣. អ្វីទៅលក្ខខណ្ឌវ្ញុអ៊ីផ្សេងទៀត ?

-ទង្វើរ៉ាយ៉ឺប

-ទង្វើស្វណាត់

៤. អ្វីខ្លះដែលធ្វើឲ្យវ្ញុអ៊ីខូច ?

**មេរៀនទី ១១**

# ស្ម៊ឡាត់

ស្ម៊ឡាត់ជាវ៉ាយ៉ិបសម្រាប់មុស្លីមប្រាំដងក្នុងមួយថ្ងៃ ។

ស្ម៊ឡាត់ជាវ៉ាយ៉ិបសម្រាប់មុស្លីមបាលិកុ (ពេញវ័យ)។ ប្រុសៗពេញវ័យ (បាលិកុ) ពេលដល់ អាយុ ១៥ ឆ្នាំយ៉ាងច្រើន ឯស្រីៗគ្រប់វ័យពេលបានដល់អាយុ ៩ ឆ្នាំ ។

ស្ម៊ឡាត់ជាមូលដ្ឋានសំខាន់បំផុតរបស់សាសនាអ៊ីស្លាម ។ ជាចំណុចចម្បងនិងជាកាតព្វកិច្ចសំខាន់បំផុតរបស់មុស្លីម ។ នៅក្នុងព្រះមហាគម្ពីរគួរអាន អល់ឡោះហ្វ៍ﷻ បានថ្លែងលើសពី ៨០ ដង ។ អល់ឡោះហ្វ៍ﷻចាត់ទុកស្ម៊ឡាត់ជាទង្វើសក្ការៈសំខាន់លើសទង្វើសក្ការៈឯទៀត ។ ស្ម៊ឡាត់ធ្វើឲ្យយើងចៀសចាកពីអំពើអាក្រក់ ហើយជួយយើងឲ្យមានជីវិតបរិសុទ្ធស្អាត ។

**ស្ម៊ឡាត់មានប៉ុន្មានប្រភេទ**?

ស្ម៊ឡាត់ខាងក្រោមនេះជាស្ម៊ឡាត់វ៉ាយ៉ិប ។

១) ស្ម៊ឡាត់ប្រចាំថ្ងៃទាំង ៥ គឺ ៖
ហ្វាជ្ជ័រ ២ រ៉ក់អ៊ាត់ ។
ស្ហ៊ុហ្វ័រ ៤ រ៉ក់អ៊ាត់ ។
អ៊ាស្ហ័រ ៤ រ៉ក់អ៊ាត់ ។
ម៉ាក់រីប ៣ រ៉ក់អ៊ាត់ ។
អ៊ីស្ហាអ៍ ៤ រ៉ក់អ៊ាត់ ។

សរុប ១៧ រ៉ក់អ៊ាត់ ក្នុងមួយថ្ងៃ ។

២) ស្វ៏ឡាត្ទុ អាយ៉ាស្វុ ។ ស្វ៏ឡាត្ទុនេះអនុវត្តនៅពេលដែលមានខែឬថ្ងៃគ្រាសរញ្ជួយដី ឬ ព្រឹត្តិការណ៍ផ្សេងទៀតដែលធ្វើឲ្យនមុស្សភ័យរន្ធត់ ។

៣) ស្វ៏ឡាត្ទុម៉ាយិត ។ គឺស្វ៏ឡាត្ទុឲ្យអ្នកស្លាប់មុនបញ្ចុះសព ។

៤) ស្វ៏ឡាត្ទុក្រោយត្ទុំវ៉ាហ្វ៉ាយ៉ូបនៅឯកាក្វុបាស្វុ ។

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ពេលណាស៊្វឡាត់ទៅជាវ៉ាយ៊ិបសម្រាប់មុស្លីម ?

២. ហេតុអ្វីបានជាស៊្វឡាត់សំខាន់សម្រាប់យើង ?

៣. ចូរប្រាប់ឈ្មោះស៊្វឡាត់ប្រចាំថ្ងៃ និងចំនួនរ៉ក់អ៊ាត់ ?

៤. អ្វីទៅស៊្វឡាត់អាយ៉ាស់ និង ស៊្វឡាត់ ម៉ាយិត ?

៥. តើមានស៊្វឡាត់វ៉ាយ៊ិបផ្សេងទៀតទេ ?

**មេរៀនទី ១២**

# ការរៀបចំខ្លួនបំពេញស្ម៏ឡាត់

មុនចាប់ផ្តើមបំពេញស្ម៏ឡាត់ គេត្រូវរៀបចំខ្លួនជាមុនសិន ។ គេហៅការរៀបចំខ្លួននេះថា ម្ញក្ញឌ៍ផ្ញាម៉ាត់ អ៊ុស្វ-ស្ម៏ឡាត់ ។

គេត្រូវរៀបចំខ្លួនដូចតទៅនេះគឺះ

១. ត៏ហ្វារ៉ត្ហ (طهارة) - ខ្លួនយើងត្រូវស្អាត ។

២. វូឌុអ៍ត្រូវប្រើទឹកស្អាតនិងថ្លា ហើយមិនក្ញស្ញ៉ប៊ី (បានមកដោយមិនត្រឹមត្រូវ) ។

៣. សំលៀកបំពាក់ត្រូវស្អាត មិនក្ញស្ញ៉ប៊ី ហើយត្រូវគ្របជិតប៉ែកដែលត្រូវតែគ្របជិតក្នុងពេលស្ម៏ឡាត់ ។

៤. ត្រូវពិនិត្យមើលទិសគ៊ីបឡាត់ឲ្យត្រឹមត្រូវ ។

៥. កន្លែង (និងកន្ទេល) ត្រូវតែស្អាត និងមិនក្ញស្ញ៉ប៊ី ។

៦. ត្រូវគោរពតាមពេលវេលា (គេមិនអាចបំពេញស្ម៏ឡាត់មុនពេលវេលាចូលមកដល់បានទេ) ។

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ម្ហូបជុំដ្ឋាម៉ាតូ អ៊ុស្វ-ស្វ៍ឡាតូមានន័យថាអ្វី ?

២. តូ៍ប្វារ៉តូមានន័យថាអ្វី ?

៣. ចូររាប់ឈ្មោះម្ហូបជុំដ្ឋាម៉ាតូ អ៊ុស្វ-ស្វ៍ឡាតូទាំងប្រាំមួយខដែលអ្នកបានសិក្សាខាងលើនេះ ហើយពន្យល់ម្ហូបជុំដ្ឋាម៉ាតូ អ៊ុស្វ-ស្វ៍ឡាតូទាំងប្រាំមួយខនេះ ។

**មេរៀនទី ១៣**

# សំលៀកបំពាក់ស្ហ៍ឡាត់

ត្រូវអនុវត្តតាមលក្ខខណ្ឌខាងក្រោមនេះ ពាក់ព័ន្ធនឹងសំលៀកបំពាក់ ។

-សំលៀកបំពាក់ត្រូវតិ៍ហ្ហៀរ (គឺបរិសុទ្ធ) ។

-សំលៀកបំពាក់ត្រូវម្វបាស៊ុ (គឺបានទទួលការអនញ្ញាត) ។

-ម្វបាស៊ុមានន័យថា ឬមួយសំលៀកបំពាក់ជាកម្មសិទ្ធិរបស់អ្នកស្របតាមច្បាប់ ឬមួយអ្នកបានទទួលការអនុញ្ញាតពីម្ចាស់សំលៀកបំពាក់ហើយ ។

-សំលៀកបំពាក់ដែលគេទិញដោយប្រាក់ ដែលមិនបានបង់ស្មាកាត់និងឃុមស៍ (خمس) ទេនោះ ត្រូវចាត់ចាត់ទុកថាកុស្ហ៍ប៊ី (គឺមិនស្របតាមច្បាប់) ។ កុស្ហ៍ប៊ីផ្ទុយពីម្វបាស៊ុ ។ ដូច្នេះ បំពេញស្ហ៍ឡាត់ជាមួយសំលៀកបំពាក់នេះត្រូវមោឃៈ (បាទិ៍ល គឺមិនត្រឹមត្រូវទេ) ។

-សំលៀកបំពាក់មិនត្រូវធ្វើមកពីប៉ែករបស់សត្វហ្ហារ៉ាំ ។ ឧទាហរណ៍ បំពេញស្ហ៍ឡាត់ជាមួយអាវដែលធ្វើអំពីរោមតោមិនសមស្របតាមច្បាប់ទេ ។

-សំលៀកបំពាក់ធ្វើអំពីប៉ែកសត្វហ្ហាឡាល់ ដែលត្រូវសំឡេះស្របតាមច្បាប់អ៊ីស្លាម អនុញ្ញាតឲ្យប្រើបាន ។

-សំលៀកបំពាក់ធ្វើអំពីប៉ែកសត្វហ្ហាឡាល់ដែលស្លាប់ខ្លួនឯង ឬត្រូវសំឡេះក្រៅច្បាប់អ៊ីស្លាម មានពីរករណីគឺៈ

ក) បើប៉ែកសត្វនោះជាប៉ែកមានជីវិត (ដូចជា ខ្លាញ់ សាច់ ស្បែក... ជាដើម) មិនអនុញ្ញាតឲ្យបំពេញស្ហ៍ឡាត់ជាមួយសំលៀកបំពាក់នោះទេ ។

ខ) បើប៉ែកសត្វនោះជាប៉ែកគ្មានជីវិត (ដូចជា រោម ស្បែង ធ្មេញ ក្រចក... ជាដើម) គេអនុញ្ញាតឲ្យបំពេញស្វ៍ឡាត់ជាមួយសំលៀកបំពាក់នោះបាន ។

**សម្រាប់តែបុរស**

-សំលៀកបំពាក់មិនត្រូវធ្វើអំពីមាសទេ ទោះជាមាសសុទ្ធក្តី មាសលាយក្តី ។ បុរសត្រូវហាមពាក់មាសគ្រប់ពេល មិនត្រឹមតែក្នុងពេលបំពេញស្វ៍ឡាត់ប៉ុណ្ណោះទេ ។

-សំលៀកបំពាក់មិនត្រូវធ្វើអំពីសូត្រសុទ្ធទេ ។ បុរសត្រូវហាមពាក់សូត្រសុទ្ធគ្រប់ពេល មិនត្រឹមតែក្នុងពេលបំពេញស្វ៍ឡាត់ប៉ុណ្ណោះទេ ។

## លំហាត់

១. ត្ញ័ហ្វៀរមានន័យថាអ្វី ?

២. មូបាស៊ូមានន័យថាអ្វី ?

៣. កុស្វ៉ប៊ីមានន័យថាអ្វី ?

៤. ប្រសិនបើសំលៀកបំពាក់ដែលអ្នកស្លៀកពាក់ក្នុងស្វ៊ឡាត្ញុំធ្វើអំពីប៉ែកសត្វ តើអ្នកត្រូវប្រយ័តអ្វីខ្លះ ?

៥. សំលៀកបំពាក់ប្រភេទណាដែលត្រូវហាមសម្រាប់បុរស ជាពិសេសក្នុងពេលបំពេញស្វ៊ឡាត្ញុំ តែអនុញ្ញាតសម្រាប់ស្ត្រី ?

**មេរៀនទី ១៤**

# កន្លែងបំពេញស្វ័ទ្បាត់

សាសនាអ៊ីស្លាមបង្គាត់បង្រៀនយើងឲ្យចេះគោរពរបស់របរ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ មិនឲ្យយើងយករបស់នោះមកប្រើដោយឥតបានទទួលការអនុញ្ញាតពីម្ចាស់របស់នោះទេ ។

ចូរគោរពតាមអនុសាសន៍ខាងលើនេះគ្រប់ពេលវេលា ជាពិសេសពេលអ្នកបំពេញស្វ័ទ្បាត់ ។

កន្លែងដែលអ្នកចង់ទៅបំពេញស្វ័ទ្បាត់ត្រូវតែជាកន្លែងរបស់អ្នក ឬមួយអ្នកបានទទួលការអនុញ្ញាតពីម្ចាស់កន្លែងនោះរួចស្រេចហើយដើម្បីបំពេញស្វ័ទ្បាត់ ។

ប្រសិនបើកន្លែងនោះមិនមែនជាកន្លែងរបស់អ្នកទេ ហើយប្រសិនបើម្ចាស់កន្លែងនោះមិនបាននុញ្ញាតឲ្យអ្នកប្រើកន្លែងនោះទេ ស្វ័ទ្បាត់របស់អ្នកនឹងមោឃៈ (បាទិ្វល) ។

ប្រសិនបើអ្នកទៅឯម៉ាស់យិ្ជដ អ្នកមិនបាច់សូមអនុញ្ញាតពីអ្នកណាទេ ។ ហេតុអ្វី ? ពីព្រោះម៉ាស់យិ្ជដជាគ្រឹះដ្ឋានរបស់អល់ទ្បោះហ្ ﷻ ដែលត្រូវសាងសង់ទ្បើងដើម្បីបំពេញស្វ័ទ្បាត់ ។

គួររំលឹកផងដែរថា អល់ទ្បោះហ្ ﷻ ចង់ឲ្យយើងបំពេញស្វ័ទ្បាត់លើកន្លែងស្អាត ។ ដូច្នេះចូរធ្វើយ៉ាងណាដើម្បីឲ្យបន្ទប់អ្នកស្អាតនិងបរិសុទ្ធ (គឺត៏ហ្វៀរ) ។

បើអ្នកមានកម្រាលសម្រាប់ស្វ័ទ្បាត់ក្នុងបន្ទប់អ្នក ចូរបត់វាទុកក្រោយពីបានបំពេញស្វ័ទ្បាត់រួច ហើយចូរទុកនៅឯកន្លែងស្អាតនិងត៏ហ្វៀរ ។

**ម៉ាស់យិជ្ជជាគេហដ្ឋានរបស់អល់ទ្បោះហ្ ដែលបានសាងសង់ទ្បើងដើម្បីស្វ័ទ្បាត់**

# លំហាត់

១. តើសាសនាអ៊ីស្លាមបង្ហាត់បង្រៀនយើងអ្វីខ្លះទាក់ទងនឹងកម្មសិទ្ធិរបស់អ្នកដទៃ ?
២. ទាក់ទងនឹងកន្លែងដែលអ្នកបំពេញស្វឡាត្ត តើចាំបាច់មានលក្ខខណ្ឌអ្វីខ្លះ ?
៣. តើលក្ខខណ្ឌទាំងនេះពាក់ព័ន្ធនឹងម៉ាស់យ៉ិដ្ឋដែរទេ ។ ហេតុអ្វី ?
៤. តើម៉ាស់យ៉ិដ្ឋជាអ្វី ? តើអ្វីទៅគោលដៅរបស់ម៉ាស់យ៉ិដ្ឋ ?
៥. ហេតុអ្វីអ្នកចាំបាច់ត្រូវថែរក្សាបន្ទប់អ្នកឲ្យស្អាតនិងត្ថូវរបៀប ?

**មេរៀនទី ១៥**

# ពេលស្វ៏ឡាត់

ប្រសើរបំផុតគឺស្វ៏ឡាត់ទាន់ពេលវេលា (គឺពេលហ្វាឌ្ហីឡាត់ ពេលដែលស្វ៏ឡាត់មានមគ្គផលល្អបំផុត) ។ បំពេញស្វ៏ឡាត់ក្នុងពេលនេះ ទទួលបាននូវផល(ស្វាវ៉ាប់)ច្រើនជាងគេ ។

ឧស្សាហ៍បំពេញស្វ៏ឡាត់ទាន់ពេលកំណត់ ធ្វើឲ្យយើងមានស្មារតីទៀងទាត់ពេលប្រសើរឡើង ។

កាលណាអំឡុងពេលស្វ៏ឡាត់ចប់ ស្វ៏ឡាត់នោះទៅជាស្វ៏ឡាត់ក្ហ៏ឌ្ហ៏ (قَضى) ។ ប្រសិនបើអ្នកមិនបានបំពេញស្វ៏ឡាត់មុនពេលដែលវាទៅជាក្ហ៏ឌ្ហ៏ទេ អ្នកត្រូវបំពេញស្វ៏ឡាត់ដោយនៀតថាក្ហ៏ឌ្ហ៏ (ជួសវ៉ាជិប) ។

បណ្តែតបណ្តោយស្វ៏ឡាត់វ៉ាជិប ឬខានបំពេញស្វ៏ឡាត់វ៉ាជិប ទាល់តែធ្វើឲ្យវាទៅជាក្ហ៏ឌ្ហ៏នោះធ្វើឲ្យខូចប្រយោជន៍និងមានទណ្ឌកម្មធ្ងន់ ។

| ឈ្មោះស្វ៏ឡាត់ | ពេលហ្វាឌ្ហីឡាត់ | ពេលក្ហ៏ឌ្ហ៏ |
|---|---|---|
| ហ្វាជ៊រ៏ (ស៊ូបហ៊្ វ) | ចាប់ផ្តើមពីពេល ស៊ូបហ៊្ វ ស្វ៏ឌិក្ហ (មុនថ្ងៃរះ) | ពេលថ្ងៃរះ |
| ឌ្ហ៊ុហ្វ៊រ៏ (កណ្តាលថ្ងៃ) | ចាប់ផ្តើមពីពាក់កណ្តាលថ្ងៃ | ពេលថ្ងៃលិច |
| អ៊ាស្វ៊រ៏ | ក្រោយស្វ៏ឡាត់ឌ្ហ៊ុហ្វ៊រ៏ | ពេលថ្ងៃលិច |
| ម៉ាក់រីប (ក្បាលព្រលប់) | ក្រោយថ្ងៃលិច | កណ្តាលយប់អធ្រាត្រ |
| អ៊ីស្ហាអ៊ុ | ក្រោយស្វ៏ឡាត់ម៉ាក់រីប | កណ្តាលយប់អធ្រាត្រ |

# លំហាត់

១. តើពេលហ្សាឌ្វីឡាត់មានន័យថាអ្វី ?

២. ពេលណាទៅស្ន៍ឡាត់ទៅជាស្ន៍ឡាត់ក្ន៍ដ្ឋ៍ តើអ្នកត្រូវធ្វើយ៉ាងណាបើវាទៅជាក្ន៍ដ្ឋ៍នោះ ?

**មេរៀនទី ១៦**

# ណាយ៉ាសាស់ (نجسة)

ណាយ៉ាសាស់គឺវត្ថុដែលស្ហារីអាស់ចាត់ទុកថាមិនបរិសុទ្ធ (គឺមិនបរិសុទ្ធយោលតាមច្បាប់សាសនា) ។

ណាយ៉ាសាស់គឺវត្ថុដែលមានធាតុដើមមិនបរិសុទ្ធ ហើយធ្វើឲ្យវត្ថុដទៃទៅជាមិនបរិសុទ្ធដោយការប៉ះពាល់ ។

វត្ថុនីមួយទៅជាណាយ៉ីស (គឺមិនបរិសុទ្ធ) ប្រសិនបើវាទៅប៉ះវត្ថុមួយទៀតដែលណាយ៉ីស បើវត្ថុណាមួយក្នុងចំណោមវត្ថុទាំងពីរនេះទទឹក ឬក៏វត្ថុទាំងពីរនេះទទឹក ។

ដូច្នេះ វត្ថុណាយ៉ីសដែលស្ងួតមិនអាចធ្វើឲ្យវត្ថុដទៃទៅជាណាយ៉ីសដែរបានទេដោយការប៉ះពាល់ ។

**ប្រភេទណាយ៉ាសាស់**

វត្ថុខាងក្រោមនេះជាណាយ៉ីសតាំងពីធាតុដើមមកម្ល៉េះ គឺះ

-ទឹកនោម
-លាមក (អាចម៍)
-ឈាម
-សាកសព (ខ្មោច)
-ឆ្កែ
-ជ្រូក
-កាហ្វៀរ
-សុរា

-ប៊ីយ៉េរ (ហ្មិក្ខក្ខ៍)

**ច្បាប់ទាក់ទងនឹងទីបន្ទោបង់**

ត្រូវចូលទៅក្នុងទីបន្ទោបង់ដោយឈានជើងឆ្វេង ។

ហាមអង្គុយបែរមុខឬបែរខ្នងដាក់គិ្ហបឡាត់ (បើទីបន្ទោបង់អ្នកបែរមុខទៅរកគិ្ហបឡាត់ចូរអ្នកអង្គុយឆៀងបន្តិច) ។

ក្រោយពីបត់ជើងតូចរួច ចាំបាច់ត្រូវលាងប៉ែកអវយវៈនោះជាមួយទឹកពីរដង (យកល្អបីដង) ។

ហាមបត់ជើងតូចឈរ ។ ធ្វើបែបនេះនឹងទទួលរងនូវទណ្ឌកម្មធ្ងន់ក្រោយពីស្លាប់ ។

ក្រោយពីបានបត់ជើងធំហើយ ត្រូវសម្អាតប៉ែកអវយវៈនោះដោយទឹក ដោយក្រណាត់ ឬ ក្រដាស់ ដោយមានលក្ខខណ្ឌថាក្រណាត់ឬប្រដាសនោះត្វ៉ហ្វៀរ (បរិសុទ្ធតាមច្បាប់សាសនា) ហើយស្ងួត ។

វ៉ាយ៉ិបត្រូវប្រើបីកំណាត់ (ក្រណាត់ឬក្រដាស) ទោះបីប៉ែកអវយៈនោះស្អាតមុនហើយក៏ដោយ ។ ប្រសិនបើក្រោយពីបានប្រើបីកំណាត់ហើយប៉ែកអវយវៈនោះនៅតែមិនស្អាត ឲ្យប្រើច្រើនកំណាត់ថែមទៀត ទាល់តែស្អាត ។

# លំហាត់

១. តើណាយ៉ាុសាស្ទមានន័យថាអ្វី ? តើវាធ្វើឲ្យវត្ថុដទៃទៅណាយ៉ឺសដូចម្ដេចទៅ ?

២. ចូររៀបរាប់ប្រភេទណាយ៉ាុសាស្ទដែលអ្នកស្គាល់ ។

៣. ទាក់ទងនឹងទីបន្ទោបង់ តើអ្វីទៅដែលហ្វារ៉ាំ ?

៤. តើអ្នកត្រូវសម្អាតដោយអ្វីទៅ បន្ទាប់ពីបត់ជើងតូចរួច ប៉ុន្មានដង ?

៥. តើអ្នកត្រូវសម្អាតដោយអ្វីទៅ បន្ទាប់ពីបត់ជើងធំរួច ប៉ុន្មានដង ?

**មេរៀនទី ១៧**

# តាក់្វលីដ្ស

ក្នុងវិស័យជីវិតនីមួយៗ យើងត្រូវការអ្នកជំនាញដែលចេះគ្រប់គ្រងវិស័យនោះ ។

ក្នុងទស្សនវិស័យនេះដែរ ពាក់ព័ន្ធនឹងរឿងច្បាប់អ៊ីស្លាម យើងត្រូវគោរពតាមវិន័យរបស់អ្នកជំនាញខាងច្បាប់ទាំងនេះ ។

គេហៅអ្នកជំនាញទាំងនេះថា មុច្ទ្ចតាហ៊្វីដ្ស (مجتهد) ឯការគោរពតាមវិន័យទាំងនេះគេហៅថា តាក់្វលីដ្ស (تقليد) ។

រាល់គ្នា ប្រុសឬស្រី ដែលគ្រប់អាយុ (បាលីក្ញុ) ត្រូវអនុវត្តតាមវិន័យទាំងនេះអាស្រ័យហ្វ៊ូរ៊្អ៊ុដ្សឌ្វីន (فروع الدين) ។

តាក់្វលីដ្សមានន័យថា គោរពច្បាប់អ៊ីស្លាមតាមវិន័យដែលមុច្ទ្ចតាហ៊្វីដ្ស (مجتهد) បានចែង ។

អ្នកដែលប្រតិបត្តិតាមវិន័យរបស់មុច្ទ្ចតាហ៊្វីដ្ស (مجتهد) គេហៅថា មុក្វល់លីដ្ស ។

ពេលនេះយើងនៅក្នុងតាក់្វលីដ្សរបស់ អាយ៉ាទុ្ហលឡោះហ្វ៍ អាល់-អ៊្ហុស្ហ៍ម៉ា សៃយីដ្សអុ្ហលី អាល់-ហ៊្វសៃនី អាស់-ស៊ីសតានី (ណាយ៉្យាហ្វ៍ អ៊ីរ៉ក្វ) ។

កាលណាគេបានដល់ប៊ូលុក្ញុ (بلوغ គ្រប់អាយុ បាលីក្ញុ) គេត្រូវនៀតថានឹងតាមការវិនិច្ឆ័យរបស់អាយ៉ាទុ្ហលឡោះហ្វ៍មួយក្នុងការប្រតិបត្តិសាសនា ។

**ប៊ូលុក្ញុ** (بلوغ)

ស្រីៗដល់ប៊្វលុក្ខ (បាលីក្ខ គឺគ្រប់អាយុ) ពេលមានអាយុ ៩ ឆ្នាំយោលតាមសាសនាអ៊ីស្លាម (តាមប្រក្រតិទិនចន្ទ្រគតិ) ។ ដូច្នេះពួកនាងត្រូវអនុវត្តតាមវ៉ាយ៉ិបទាំងអស់ ។ ប្រុសៗដល់ប៊្វលុក្ខពេលមាន អាយុ ១៥ ឆ្នាំពេញ ។

## លំហាត់

១. អ្វីទៅមុច្ចតាហ្វ៊ីដូ ?

២. តាក់ូលីដូមានន័យថាអ្វី វាទៅជាវ៉ាឃ្មើបពេលណា ?

៣. មូក្ខុល់លីដូមានន័យថាអ្វី ?

៤. ប៊ូលុក្កមានន័យថាអ្វី ពេលណាទៅប្រុសៗនិងស្រីៗដល់ប៊ូលុក្ខ ?

៥. តើអ្នកនៅក្នុងតាក់ូលីដូរបស់អ្នកណា ?

**មេរៀនទី ១៨**

# សាឡើងវិញ

**១) អល់ឡោះហ្វ៍**

រាល់ពេលដែលយើងថា "អល់ឡោះហ្វ៍" យើងត្រូវថាបន្ថែមថា "ស៊ុបហ្ហាណាហ្វ្ វ៉ាតាអាឡា" ។

**២) ព្រះសាស្តា**

ក) អល់ឡោះហ្វ៍ﷻបានចាត់បញ្ជូនមក ១២៤០០០ ព្រះសាស្តាعليهم السلام ។ ព្រះសាស្តាعليهم السلام ទាំងអស់នេះសុទ្ធតែត្រឹមត្រូវតាមសច្ចធម៌ ។

ខ) ព្រះសាស្តាមុនគេបង្អស់គឺអាដាំعليه السلام ។ ព្រះសាស្តាចុងក្រោយបង្អស់គឺមូហាំម៉ាដ់ មុស្តហ្វាﷺ ។

**៣) ព្រះសាស្តាអ៊ូលុល-អាស៊្ម៍ (أولو العزم)**

អ៊ូលុល-អាស៊្ម៍ គឺព្រះសាស្តាធំធ្ងើង មាន ៥ អង្គគឺ ៖

- **ព្រះសាស្តា នុះហ៍عليه السلام ។**
- **ព្រះសាស្តា អ៊ិបរ៉ហ៊ីមعليه السلام ។**
- **ព្រះសាស្តា មូសាعليه السلام ។**
- **ព្រះសាស្តា អ៊ីសាعليه السلام ។**
- **ព្រះសាស្តា មូហាំម៉ាដ់ មុស្តហ្វាﷺ ។**

## ៤) ព្រះគម្ពីរ

ព្រះគម្ពីរត្រូវបើកឲ្យដឹងដូចតទៅគឺ ៖

ព្រះគម្ពីរតៅរ៉ត្ត ត្រូវបើកឲ្យព្រះសាស្តាមូសាعليه السلامដឹង ។
ព្រះគម្ពីរស្ហាប៊ូរ ត្រូវបើកឲ្យព្រះសាស្តាដាវូដعليه السلامដឹង ។
ព្រះគម្ពីរអ៊ីនយ៉ីល ត្រូវបើកឲ្យព្រះសាស្តាអ៊ីសាعليه السلامដឹង ។
ព្រះគម្ពីរគួរអានត្រូវបើកឲ្យព្រះសាស្តាមូហាំម៉ាដ់ﷺយើងដឹង ។

## ៥) អាស្ហ់លុល-បៃត៍

អាស្ហ់លុល-បៃត៍មាន ១៤ អង្គគឺ ៖

ព្រះសាស្តាមូហាំម៉ាដ់ﷺយើង ហ្វាទីម៉ាស្ហ់ អាស្ហ់-ស្ហាស្ហ់រ៉អ៊ ៍سلام الله عليها ព្រះរាជបុត្រីរបស់ព្រះអង្គﷺ និងអ៊ីម៉ាំعليهم السلامទាំង ១២ អង្គ ។

តើអ្នកស្គាល់ឈ្មោះអ៊ីម៉ាំعليهم السلامយើងទាំង ១២ អង្គទេ ?
ពេលគេថាឈ្មោះអ៊ីម៉ាំយើងអង្គណាមួយ យើងត្រូវថា "អ៊ាឡៃហ្ហ៊ី អាឡាម" ។
ពេលគេថាឈ្មោះប៊ីប៊ីហ្វាទីម៉ាស្ហ់ យើងត្រូវថា "អ៊ាឡៃហ្ហា សាឡាម" ។

ពេលថាឈ្មោះអាស្ហ់លុល-បៃត៍ យើងត្រូវឱនក្បាលដើម្បីសម្ដែងសេចក្ដីគោរព ហើយត្រូវស្វូត្រស្វ៍ឡាវ៉ាត ។

ព្រះសាស្តាﷺយើងមានព្រះវចនៈថា៖ "អ្នកណាមិនស្វូត្រស្វ៍ឡាវ៉ាត បន្ទាប់ពីបានថា ឬបានឮឈ្មោះអាស្ហ់លុល-បៃត៍អង្គណាមួយទេ អ្នកនោះជាបុគ្គលកំណាញ់ ។"

## ៦) តាស់ប៊ិះហ្វ៍

ក្រោយពីស្វ៍ឡាត្ហ់ភ្លាម មុសតាហ្ហាប់ (ស្ហូណាត្ហ់)

ឲ្យសូត្រតាស់ប៊ីះហ៍ហ្វាទិម៉ាស់ដូចតទៅគឺ ៖

| | |
|---|---|
| អល់ឡ៍ហ្វូ អាក់បារ (អល់ឡោះហ៍មហាធំធ្ងើងបំផុត) | ៣៤ ដង |
| អាល់ហ៊ាំឌូលិលឡាស់ (អល់ឡោះហ៍ជាទីស្ញើចសរសើរ) | ៣៣ ដង |
| ស៊ុបហ៊ាណល់ឡោះហ៍ (អល់ឡោះហ៍មហារុងរឿង) | ៣៣ ដង |

## ៧) ទេវតា

ទេវតាមានចំនួនច្រើន ហើយមើលមិនឃើញទេ ។ ទេវតាបំពេញភារកិច្ចច្រើនរាប់មិនអស់ ដែលអល់ឡោះហ៍ដាក់មកលើអស់ព្រះអង្គ ។ អស់ទេវតាថ្វាយសេចក្ដីស្ញើចសរសើរចំពោះអល់ឡោះហ៍និងគោរពព្រះបញ្ជាព្រះអង្គ ។ ទេវតាមួយចំនួនរូគុអ៊ុំនៅឋានសួគ៌ ទេវតាឯទៀតស៊ូយ្ជុដ្ង រីឯទេវតាមួយចំនួនទៀតធ្វើសក្ការបូជាអល់ឡោះហ៍រៀងរហូតលុះដល់ថ្ងៃជំនុំជម្រះ ។

ទេវតាបួនអង្គ ក្នុងចំណោមទេវតាទាំងនេះ ដែលគេស្គាល់ជាងគេគឺ ៖

**យ៉ីបរ៉អ៊ីល**ﷺ-ទេវតាដែលនាំព្រះបញ្ជា និងព្រះរាជសាររបស់អល់ឡោះហ៍មកឲ្យព្រះសាស្ដា ។ ព្រះអង្គﷺនាំអាយ៉ាត់គួរអានមកឲ្យព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺ ។

**មីកាអ៊ីល**ﷺ-ទេវតាដែលចែកគ្រឿងទ្រទ្រង់ជីវិតឲ្យយើង (រីស្ស៊ីគ្នី) ពោលគឺ អាហារសំលៀកបំពាក់និងជម្រក ។ អល់ឡោះហ៍ប្រទានឲ្យយើងនូវរបស់ចាំបាច់សម្រាប់ជីវិត ។

**អ៊ីសរ៉ហ៊្វីល**ﷺ-ទេវតាដែលនឹងផ្លុំស្នែងមុនគ្នីយ៉ាម៉ាត់ និងដែលធ្វើឲ្យអ្វីៗដែលមានជីវិតវិនាស ។ ព្រះអង្គﷺនឹងផ្លុំស្នែងលើកទីពីរដើម្បីធ្វើឲ្យអ្នកស្លាប់ទាំងអស់រស់ឡើងវិញ ។ បន្ទាប់ពីនោះគឺថ្ងៃជំនុំជម្រះ(គ្នីយ៉ាម៉ាត់) ។

**អ៊ីស្សរ៉អ៊ីល**ﷺ-ទេវតាដែលដកព្រលឹងមនុស្ស ។ គេស្គាល់ព្រះនាមរបស់ទេវតាអង្គនេះជាងគេថា "មច្ចុរាជ" (ទេវតានៃសេចក្ដីស្លាប់ ملك الموت) ។

ក្រៅពីអគ្គទេវតាទាំងបួនអង្គនេះ មានទេវតាច្រើនអង្គទៀតគឺ ៖

**រ៉ាគីប**ﷺ-ទេវតាដែលកត់អំពើល្អរបស់យើងទុក ។ ទេវតាអង្គនេះនៅលើស្មាស្តាំយើង ។

**អាទីដ**ﷺ-ទេវតាដែលកត់អំពើអាក្រក់របស់យើងទុក ។ ទេវតាអង្គនេះនៅលើស្មាឆ្វេងយើង ។

ទេវតាទាំងនេះមាននាទីកត់ទង្វើទាំងអស់របស់យើងនៅក្នុងបញ្ជី ។ បញ្ជីទាំងនេះមានមុខងាររំលឹកឡើងវិញទង្វើល្អនិងទង្វើអាក្រក់របស់យើង ក្នុងថ្ងៃគីយ៉ាម៉ាត់ ។ ដូច្នេះ ទោះបីយើងបានភ្លេចទង្វើរបស់យើងក៏ដោយ ទេវតាទាំងនេះនឹងមិនភ្លេចកត់ទុកទង្វើទាំងនេះក្នុងបញ្ជីនោះទេ ។

# លំហាត់

១. តើអ្នកត្រូវសូត្រអ្វីក្រោយពីបានថា "អល់ឡោះហ្វ៊" ?

២. តើប៉ុន្មានព្រះសាស្តាដែលត្រូវចាត់បញ្ជូនមកបង្ហាត់បង្រៀនយើង ? ព្រះសាស្តាណាជាព្រះសាស្តាមុនគេបង្អស់ ? ព្រះសាស្តាណាជាព្រះសាស្តាក្រោយគេបង្អស់ ?

៣. តើអ៊ូលុល-អ៊ុស្ម៍មានន័យថាអ្វី ? ចូររាប់ឈ្មោះអ៊ូលុល-អ៊ុស្ម៍ទាំងនោះ ?

៤. ចូររាប់ឈ្មោះព្រះគម្ពីរ តើព្រះគម្ពីរទាំងនេះត្រូវដាក់មកឲ្យអ្នកណាខ្លះ ។

៥. ចូរឲ្យព្រះនាមរបស់អាស្វលុល-បៃត៍ទាំងអស់ ។

៦. តើអ្នកត្រូវសូត្រអ្វីក្រោយពីបានថាព្រះនាមរបស់អាស្វលុល-បៃត៍ ?

៧. តើសូត្រអ្វីខ្លះក្នុងតាស់ប៊ិះហ្វ៊ហ្វាទីម៉ាស្វ ? ប៉ុន្មានដង ?

៨. ចូរឲ្យព្រះនាមអគ្គទេវតាទាំងបួនអង្គ ។ តើទេវតាទាំងនេះមានមុខងារអ្វី ?

៩. តើទេវតាកត់ទង្វើល្អរបស់យើងមានព្រះនាមអ្វី ?

១០. តើទេវតាកត់ទង្វើអាក្រក់របស់យើងមានព្រះនាមអ្វី ?

**មេរៀនទី ១៩**

# ទង្វើវ៉ាយ៊ីបក្នុងស្ហ៍ឡាត់

(រុកន៍ (ركن) និង កុយ់រ៉ រុកនី)

អ្នកដឹងស្រាប់ហើយថាក្នុងស្ហ៍ឡាត់មានច្រើនប៉ែក ។ ក្នុងមេរៀននេះអ្នកនឹងបានដឹងនូវតារាងទង្វើវ៉ាយ៊ីបក្នុងស្ហ៍ឡាត់ ។

ក្នុងស្ហ៍ឡាត់មានខវ៉ាយ៊ីប ១០ ខ គឺ ៖

**១. នៀត**

បំណងបំពេញស្ហ៍ឡាត់ "គួរបាតាន់ អ៊ីលឡុលឡោះហ្វ៍" ។

**២. តាក់ប៊ីរ៉ទុល អិះហ្ស៍រ៉ម**

"អល់ឡ៍ហ្វ៊ូ អាក់បារ" ទី ១ ។

**៣. គ៊ីយ៉ាម**

ឈរស្ងួត្រ

**៤. គ៊ីរ៉អាត់** (قراءات)

ស្ងួត្រក្នុងគ៊ីយ៉ាម

**៥. រូគុអ៊ុ**

បង្អោនខ្លួន

**៦. សាច់ដ្ងាស់ទាំងពីរ**

ក្រាបប្រណិប័តន៍ ។ ថ្ងាស ជង្គង់ បាតដៃទាំងពីរ មេជើង ប៉ះផ្ទៃកម្រាល ។

**៧. ស៊ីក៍ (ឬ ស៊ីកៀរ)**

សូត្រក្នុងគ្វីយ៉ាមនិងក្នុងសាច់ដ្វាស់ ។

**៨. តាស្ហ្វាស់ហ្វ៊ីង**

**៩. សាឡាម**

**១០. តារទីប** (ترتيب) **និង មូវ៉ាឡាត់**

ស្វ៊ូឡាត់ប្រៀបបាននឹងសំណង់ដែលមានច្រើនប៉ែក ។ ប៉ែកមួយចំនួនជាគ្រឹះរបស់សំណង់ ឯមួយចំនួនទៀតនៅពីលើគ្រឹះ ។ ប្រសិនបើគ្រឹះមិនមាំទេសំណង់នឹងរលំ ។

ដូចគ្នាដែរ ទង្វើវ៉ាយ៊ីបក្នុងស្វ៊ូឡាត់បែងចែកជាពីរប្រភេទគឺ៖ **រុកន៍** (រូកុន) និង **កុយ៉រ៉ រុកនី** (មានន័យថា មិនមែនរូកុនដាច់ខាតខានមិនបាននោះទេ ពោលគឺជារូកុន អនុលោម) ។

**រុកន៍** (រូកុន) ជាប៉ែកនានារបស់ស្វ៊ូឡាត់ដែលជាគ្រឹះ (គឺជាវ៉ាយ៊ីបខានមិនបានជាដាច់ខាត) ។

**កុយ៉រ៉ រុកនី**ជាប៉ែកនានាដែលមិនមែនជាប៉ែករបស់គ្រឹះទេ (មិនមែនជាវ៉ាយ៊ីបខានមិនបានជាដាច់ខាតនោះទេ ពោលគឺ ជារូកុនអនុលោម) ។

# លំហាត់

១. ចូរសរសេរ ១០ ខ ដែលជាវ៉ាឃ្យ៉ីបក្នុងស្វ៍ឡាត្ត់ ដោយអធិប្បាយខនីមួយៗ ។

២. តើរុកន៍មានន័យថាអ្វី ?

៣. តើក៊ុយ៉ រុកនីមានន័យថាអ្វី ?

៤. ស្វ៍ឡាត្ត់ប្រៀបបាននឹងសំណង់ដូចម្ដេចទៅ ? ចូរអធិប្បាយដោយសំអាងលើរុកន៍ និងក៊ុយ៉ រុកនី ។

កំណែលើកទី ២, 06/2020